ការនិទានរឿងបង្កើតឱ្យមានទំនាក់ទំនង
ការចែករំលែកក្តីស្រឡាញ់ ភាព
សប្បាយរីករាយ ការស្រមើស្រមៃ
ការទទួលបទពិសោធ និងសេចក្តីសុខ
ទាំងអស់គ្នា។

ទម្លាប់រស់នៅល្អ មិត្តភាពបវរ អនាគតរុងរឿង

jica

Social Welfare Corporation
TENRYU-KOHSEIKAI

SVA
Shanti Volunteer Assoc.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# រឿងនិទានសម្រាប់កុមារតូច









នាយកដ្ឋានអប់រំកុមារតូច   អង្គការសន្តិស្ម័គ្រចិត្ត (SVA)

ឆ្នាំ២០២៤

Scanned with
MOBILE SCANNER

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# រឿងនិទានសម្រាប់កុមារតូច









នាយកដ្ឋានអប់រំកុមារតូច   អង្គការសន្តិស្ម័គ្រចិត្ត (SVA)

ឆ្នាំ២០២៤

Scanned with
MOBILE SCANNER

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍកុមារតូចពេញលេញ និងគ្រប់ជ្រុងជ្រោយ កែលម្អលទ្ធផលសិក្សាពេញមួយជីវិតរបស់កុមារកម្ពុជា ឱ្យពួកគេក្លាយជាមនុស្សពេញវ័យប្រកបដោយគុណសម្បទាពលរដ្ឋសកល និងដើម្បីកសាងសង្គមកម្ពុជាមានភាពចម្រើនរុងរឿង និងសុខសន្តិភាព។

ការអភិវឌ្ឍកុមារតូច គឺជាអន្តរកម្មជាមួយកុមារទៅនឹងបរិស្ថាន វត្ថុ មនុស្ស ធម្មជាតិ និងបាតុភូត ដែលនៅជុំវិញ។ ក្នុងដំណាក់កាលនេះ កុមារតូចចាប់ផ្តើមចេះសង្កេត បទពិសោធន៍ មានទម្លាប់ល្អ កត់សម្គាល់ព្រឹត្តការណ៍ដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងបរិស្ថានតាមរយៈសកម្មភាពការលេងបែបធម្មជាតិ ឬសម្ភារៈផ្សេងៗ។

ដើម្បីឱ្យកុមារមានការអភិវឌ្ឍប្រកបដោយភាពឆ្លើយតប សាលាមត្តេយ្យសិក្សា និងគ្រូបង្រៀនចាំបាច់ត្រូវមានសមត្ថភាពសម្បូរបែបក្នុងការដឹកនាំ និងផ្តល់ឱកាសឱ្យកុមារបានអនុវត្តសកម្មភាពលេងជាមួយសម្ភារៈល្បែងសិក្សា ក្នុងបរិស្ថានស្អាត បៃតង សុវត្ថិភាព ផាសុកភាព និងមេត្រីភាពស្របតាមទ្រឹស្តី **«រៀនតាមរយៈការលេង និងបរិស្ថាន»និង«ការលេងគឺជាការរៀនរបស់កុមារតូច»**។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារគន្លឹះជាជំនួយផ្នែកវិធីសាស្ត្រសម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សាក្នុងការផលិត និងច្នៃប្រឌិតតាមទម្រង់ប្រភេទសម្ភារៈល្បែងសិក្សា និងដំណើរការរៀបចំបរិស្ថានសិក្សា ជាពិសេសវិធីសាស្ត្រអនុវត្តសកម្មភាពនៃការនិទានរឿង ក្នុងគោលដៅអភិវឌ្ឍន៍បំណិនពុទ្ធិ និងបំណិនមិនមែនពុទ្ធិរបស់កុមារតូច ឱ្យកាន់តែប្រសើរឡើង តាមលក្ខណៈវិទ្យាសាស្ត្រ។

ក្រសួងអប់រំ យុវជន និងកីឡា មានសុទិដ្ឋិនិយមថា គ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងគ្រូបង្រៀនមត្តេយ្យសិក្សា នឹងចូលរួមសហការនិងគាំទ្រដល់ការអនុវត្តឯកសារនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារតូចនៅកម្ពុជា ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកជំទាវ **គីម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា ជាប្រធានគណៈកម្មការគ្រប់គ្រងនិងរៀបចំចងក្រងឯកសារ **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) អង្គការសន្តិស្ម័គ្រចិត្ត(SVA)** ជាពិសេស**សាជីវកម្មសុខុមាលភាព ចិនរីយុ កូសៃកៃ(TKK)** **ប្រទេសជប៉ុន មន្ត្រីជំនាញនាយកដ្ឋានអប់រំកុមារតូច** ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម និងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ដឹកនាំរៀបចំតាក់តែងឯកសារសម្រាប់ការអប់រំកុមារតូចនេះ ឱ្យសម្រេចជាផ្លែផ្កាឡើងនាខណៈនេះ។

ថ្ងៃព្រហស្បតិ៍ [illegible] ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

Scanned with MOBILE SCANNER

## គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| លោកជំទាវ **គឹម សេដ្ឋានី** | លោកជំទាវ **ឃុន រចនា** | ឯកឧត្តម **ពុត សាមិត្ត** |
| ឯកឧត្តម **ឡោ ឆវណ្ណា** | ឯកឧត្តម **ប្រាក់ កុសល** | លោកស្រី **ផ្លុង មុនីកុសល** |
| ឯកឧត្តម **ឈួន ម៉ុនឈឿន** | លោក **ឃិន ធី** | លោក **ឃី សុខគី** |
| លោក **តាកាស៊ី ការសេ** | លោកស្រី **អាយ៉ាណុ គិគុជិ** | |

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| លោក **ប៉ាត់ គឹមលីន** | លោក **ឆន ឈាង** | លោកស្រី **ឌុយ គឹមច័ន្ទដារី** |
| លោកស្រី **រ័ត្ន ម៉ារិន** | លោកស្រី **ម៉ៅ ណាវី** | លោកស្រី **ហេង ចាន់ណា** |
| លោកស្រី **សាំនី លីពី** | លោក **សេង វ៉ាស៊ីន** | លោក **ហ៊ឹម អក្កដា** |
| លោកស្រី **សុខ អេង** | លោកស្រី **រស់ សិរីនិមល់** | លោក **សៀង គឹមឈឿន** |
| លោកស្រី **ជា ដូរ៉ានី** | លោកស្រី **ឆៃ ស្រីមុំ** | លោក **គួន ម៉ុងក្រាត់** |
| លោកស្រី **ហួន សុធារ័ត្ន** | លោក **ស៊ុម ហឿន** | កញ្ញា **យ៉ា ហ្សារីណា** |
| កញ្ញា **ធីង ធិច័ន** | | |

## ទីប្រឹក្សាបច្ចេកទេស

សាជីវកម្មសុខុមាលភាពសង្គម ជិនរីយូ កូសេកៃ (TKK)

## ក្រុមការងារសម្របសម្រួល

លោកស្រី **អាយ៉ាណុ គិគុជិ** លោក **យន់ វាសនា** លោកស្រី **អ៊ីស៊ីសុកា សាគី**

## គណៈកម្មការពិនិត្យ

| | | |
|---|---|---|
| ឯកឧត្តម **ឈួន ម៉ុនឈឿន** | លោក **ឃិន ធី** | លោក **ឃី សុខគី** |
| | លោក **ប៉ាត់ គឹមលីន** | |

## គាំទ្រដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)

## អារម្ភកថា

ការរៀបចំឯកសារនេះឡើងក្នុងគោលបំណងដើម្បីពន្លឿនដល់ការអភិវឌ្ឍរបស់កុមារតូច តាមរយៈអន្តរកម្មជាមួយការលេង និងបរិស្ថាន ដែលមានសារៈសំខាន់គប្បីគ្រូមត្តេយ្យសិក្សាមានមូលដ្ឋានរៀបចំបរិស្ថានប្រកបដោយការច្នៃប្រឌិតខ្ពស់ និងផ្តល់ឱកាសឱ្យកុមារចូលរួមសម្រាប់ធ្វើសកម្មភាពឱ្យបានគ្រប់គ្នា។ ក្នុងការអនុវត្តទ្រឹស្តី «រៀនតាមរយៈការលេង និងបរិស្ថាន» ជួយដល់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងគុណភាព។

ឯកសារស្តីពីរឿងនិទានសម្រាប់កុមារតូចបានជួយឱ្យគ្រូមត្តេយ្យសិក្សារៀបចំសកម្មភាពបង្រៀនប្រចាំថ្ងៃជាមួយកុមារឱ្យកាន់តែមានទាក់ទាញ និងភាពសប្បាយរីករាយដោយប្រើប្រាស់សៀវភៅរឿងនិទាន ដើម្បីឱ្យកុមារទទួលបានមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការសិក្សាពេញមួយជីវិត។ ឯកសារស្តីពីរឿងនិទានសម្រាប់កុមារតូច បានចងក្រងបទពិសោធជាក់ស្តែងរបស់គ្រូមត្តេយ្យសិក្សា ក្រុមការងារបច្ចេកទេសគម្រោងដែលមានបទពិសោធអប់រំកុមារតូចរយៈពេលច្រើនឆ្នាំ និងប្រឹក្សាបច្ចេកទេសពីគ្រូមត្តេយ្យសិក្សានៅសាជីវកម្មសុខុមាលភាពសង្គម ជិនរីយូកូសេកៃ ខេត្តស៊ីហ្សូកាប្រទេសជប៉ុន។

គណៈកម្មការនិពន្ធបានខិតខំសិក្សាស្រាវជ្រាវ និងអភិវឌ្ឍឯកសារនេះរួមមាន ការនិទានរឿង វិធីសាស្ត្រក្នុងការនិទានរឿង របៀបផលិតសម្ភារសម្រាប់និទាន តំណភ្ជាប់សកម្មភាពនិទានរឿង និងផ្សព្វផ្សាយការអាននៅផ្ទះ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយជាឯកសារជំនួយស្មារតីដល់លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់យកទៅប្រើប្រាស់ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព។

យើងខ្ញុំរង់ចាំទទួលនូវរាល់មតិស្ថាបនា ផ្តល់ជាគំនិតយោបល់ ក្នុងការចូលរួមចំណែកកែលម្អ ដើម្បីឱ្យឯកសារនេះកាន់តែមានខ្លឹមសារល្អប្រសើរ។

គណៈកម្មការនិពន្ធ និងរៀបរៀង

Scanned with MOBILE SCANNER

# មាតិកា


**សេចក្តីផ្តើម** ..... **១**

**ជំពូកទី១. រឿងនិទាន** ..... **២**

១. ការនិទានរឿង និងការបង្រៀនរឿងនិទាន ..... ៤

១.១ ការនិទានរឿង ..... ៤

១.២ ការបង្រៀនរឿងនិទាន ..... ៥

២. សារៈសំខាន់ និងប្រសិទ្ធភាពរឿងនិទាន ..... ៥

**ជំពូកទី២. ការអនុវត្តការនិទានរឿង** ..... **១០**

១. មូលដ្ឋានគ្រឹះនៃការនិទានរឿង ..... ១២

២. ដំណើរការនិទានរឿង ..... ១៥

៣. គន្លឹះទាញអារម្មណ៍កុមារឱ្យផ្ចង់ស្តាប់ការនិទានរឿង ..... ១៦

**ជំពូកទី៣. ប្រភេទរឿងនិទាន** ..... **១៩**

១.និទានរឿងដោយផ្ទាល់មាត់ ..... ២២

២.និទានរឿងដោយសៀវភៅរូបភាព ..... ២៤

៣.និទានរឿងដោយផ្ទាំងរូបភាព ..... ២៦

- និទានរឿងដោយផ្ទាំងរូបភាព ..... ២៦
- និទានរឿងដោយក្តារខៀន ឬផ្ទាំងសំពត់សំឡី ..... ២៨

៤. និទានរឿងដោយតុក្កតា ឬអាយ៉ង (តុក្កតា ស្រោមដៃ រូបដោត អាវអៀម) ..... ៣០

- និទានរឿងដោយតុក្កតា ..... ៣០
- និទានរឿងដោយស្រោមដៃ ..... ៣៤
- និទានរឿងដោយរូបដោត ..... ៣៦
- និទានរឿងដោយអាវអៀម ..... ៤០

៥. និទានរឿងបណ្តើរ គូររូបបណ្តើរ ..... ៤២

៦. និទានរឿងដោយសម្តែងតួតាមសាច់រឿង (កុមារដើរតួផ្ទាល់) ..... ៤៤

**ជំពូកទី៤. ការអភិវឌ្ឍន៍ការនិទានរឿងទៅជាសកម្មភាពផ្សេងៗ** ..... **៤៦**

**ជំពូកទី៥. ការលើកកម្ពស់ការអាននៅផ្ទះ** ..... **៥៨**

១. សារៈសំខាន់នៃការអាននៅផ្ទះ ..... ៦០

២. របៀបជំរុញការអាននៅផ្ទះ ..... ៦២

**ជំពូកទី៦. ការងារបណ្ណាល័យមត្តេយ្យសិក្សា** ..... **៧២**

១. ការគ្រប់គ្រងសៀវភៅ ..... ៧៥

២. ការខ្ចី សងសៀវភៅ ..... ៨៥

៣. ការការពារ និងថែរក្សាឯកសារ ..... ៨៧


Scanned with MOBILE SCANNER

# របៀបប្រើប្រាស់ឯកសារ

ឯកសារស្ដីពីរឿងនិទានមាន៦ជំពូក។ ជំពូកទី១ ផ្ដោតទៅលើទ្រឹស្ដីអំពីសារៈសំខាន់នៃរឿងនិទាន ជំពូកទី២ ផ្ដល់នូវមូលដ្ឋានគ្រឹះនៃការដំណើរការសកម្មភាពរឿងនិទាននៅកម្រិតមត្តេយ្យសិក្សា ជំពូកទី៣បង្ហាញនូវរបៀបដំណើរការរឿងនិទានតាមប្រភេទនៃការនិទានរឿង និងជំពូកទី៤ដល់ទី៦ និយាយពីការប្រើប្រាស់រឿងនិទានក្នុងសកម្មភាពបង្រៀនក្នុងសាលា និងការអាននៅផ្ទះ ភ្ជាប់ជាមួយនឹងសកម្មភាពបណ្ណាល័យដើម្បីបន្តជំរុញការអាន។

## ទម្រង់អត្ថបទ

នៅក្នុងជំពូកទី៣ ប្រភេទរឿងនិទាន អត្ថបទត្រូវបានរៀបចំដូចខាងក្រោម៖

៤. និទានរឿងដោយតុក្កតា ឬស្រមោល (តុក្កតា ស្រោមដៃ ស្រមោល ...)

- និទានរឿងដោយតុក្កតា



**១.សេចក្ដីផ្ដើម៖**

ការជ្រើសរើសយកតុក្កតាមកប្រើឱ្យការនិទានរឿង ដោយសារកុមារនិយមចូលចិត្តលេងតុក្កតា ដូច្នេះហើយការនិទានរឿងដោយប្រើតុក្កតាធ្វើឱ្យមានប្រសិទ្ធភាពក្នុងការសិក្សារបស់កុមារ។ រឿងដែលជ្រើសរើសយកមកនិទាន ត្រូវឱ្យសមស្របទៅតាមវ័យរបស់កុមារមិនត្រូវមានឈុតឆាក និងតួអង្គច្រើនពេកនោះទេ។

១. សម្ភារឧបទេស

និទានរឿងដោយប្រើតុក្កតា គឺជាការនិទានរឿងដោយយកតុក្កតាជាតំណាងឱ្យតួអង្គទាំងឡាយនៅក្នុងរឿងនិទាន ដូចជា មនុស្ស សត្វ បន្លែ ផ្លែឈើជាដើម។ គ្រូអាចផលិតតុក្កតាដោយខ្លួនឯង ឬក៏អាចទិញនៅតាមទីផ្សារបានឱ្យតែសមស្របទៅតាមសាច់រឿងដែលត្រូវយកមកនិទាន។

របៀបផលិត



...រូបតួអង្គ រូបកាត់រូបចេញពីផ្ទាំងក្រដាស ៣. ដាក់ពណ៌រូបតួអង្គ

**២.សម្ភារឧបទេស៖** ការនិទានរឿងខ្លះចាំបាច់ត្រូវមានសម្ភារ ដែលអាចផលិតដោយអ្នកនិទានខ្លួនឯងផ្ទាល់ ឬទិញពីផ្សារ។ ក្នុងឯកសារនេះ យើងមានបង្ហាញរបៀបងាយៗនៃការផលិតសម្ភារទាំងនោះផងដែរ។

២. របៀបនិទានរឿង

- ពិនិត្យ និងរៀបចំតុក្កតាផ្ដាប់តាមលំដាប់លំដោយនៃសាច់រឿង
- ពេលនិទានត្រូវលើកតួអង្គតុក្កតាបង្ហាញតាមឆាកឈុតនៃសាច់រឿង បញ្ចេញតួអង្គម្ដងមួយៗ កាន់បង្ហាញកុំឱ្យបាំងផៃ ប្រែប្រួលទឹកមុខ លើកដាក់សំឡេង រក្សាសំឡេង របស់តួអង្គនីមួយៗ។ ក្នុងករណីតួអង្គពីរជជែកគ្នា ត្រូវប្រើដៃទាំងពីរកាន់តុក្កតាម្ខាងមួយ និងធ្វើកាយវិការតាមសកម្មភាពតួអង្គ។ តួអង្គណាដែលបង្ហាញរួចហើយ អាចផ្កាប់រូបចុះក្រោម។
- ពោល និងពណ៌នាតាមដំណើររឿងដោយប្រើសំឡេងធម្មជាតិ។

**៣. របៀបនិទានរឿង៖** ផ្ដល់នូវគន្លឹះសំខាន់ៗសម្រាប់ជួយឱ្យការនិទានរឿងតាមប្រភេទនីមួយកាន់តែមានភាពរលូន ភ្ជាប់ជាមួយរូបភាព។







Scanned with MOBILE SCANNER

ឧទាហរណ៍ការនិទានរឿងដោយកុមារបន្ទាប់ពីស្តាប់រឿងនិទានចប់



### ឧទាហរណ៍៖

ដើម្បីឱ្យយល់កាន់តែច្បាស់ពីផ្នែកទ្រឹស្តីមួយចំនួន ឯកសារនេះមានបន្ថែមនូវឧទាហរណ៍ជាច្រើន ដែលបានដកស្រង់ចេញពីបទពិសោធដែលបានអនុវត្តន៍ដោយសាលា ឬគ្រូមត្តេយ្យសិក្សា។ សារតា វត្ថុបំណង និងលទ្ធផលរបស់សកម្មភាពត្រូវបានបង្ហាញជូនផងដែរ។

ឧទាហរណ៍របៀបជំរុញការអាននៅផ្ទះ:





### គន្លឹះបន្ថែម

គន្លឹះបន្ថែមផ្តល់ឱ្យអ្នកអាននូវគំនិតថ្មីៗបន្ថែម។ ឧទាហរណ៍ ការផលិតតុក្កតា ក្រៅពីផលិតដោយគូរគំនូរ អ្នកនិទានអាចច្នៃប្រឌិតពីកំណាត់ជីឥដ្ឋ ស្រោមជើងចាស់ៗ ឬបន្លែសំណល់ផ្ទះ[illegible]។

Scanned with MOBILE SCANNER

# សេចក្តីផ្តើម

ក្នុងពិភពលោកគ្មានកុមារណាម្នាក់ដែលមិនចូលចិត្តស្តាប់រឿងនិទាននោះទេ។ សៀវភៅរឿងនិទានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយពន្លឿនការអភិវឌ្ឍអន្តរកម្មរវាងកុមារជាមួយបរិស្ថាន និងការលេង។ ខ្លឹមសាររឿងនិទាននីមួយៗ បានផ្តល់គន្លឹះសំខាន់ៗ ដោយផ្សារភ្ជាប់ទៅនឹងទ្រឹស្តី និងចំណេះដឹងដែលមានស្រាប់ជាទុនដ៏ប្រសើរក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ។ លើសពីនេះទៀត ចំណេះដឹងរបស់កុមារមិនមែនត្រឹមតែទទួលបានពីគ្រូ និងមាតាបិតាប៉ុណ្ណោះទេ គឺកុមារទទួលបានចំណេះដឹងពីគ្រប់មជ្ឈដ្ឋានទាំងវិជ្ជមាន និងអវិជ្ជមាន ដូច្នេះការរៀបចំផែនការសកម្មភាព និងការរៀបចំបរិស្ថានមានសារៈសំខាន់ណាស់ ដើម្បីជំរុញលើកទឹកចិត្តឱ្យកុមារចូលរួមអនុវត្តន៍សកម្មភាពទាំងនោះជាកត្តានាំឱ្យការរៀនសូត្ររបស់កុមារទទួលបានជោគជ័យពេញមួយជីវិត។

សៀវភៅរឿងនិទានបានរួមចំណែកផ្តល់ចំណេះដឹងសម្រាប់ការសិក្សាបំណិនរូបវន្ត និងអភិវឌ្ឍន៍បំណិនអរូបវន្ត ពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ គុណតម្លៃ។ តាមរយៈការស្តាប់រឿងនិទាន ធ្វើឱ្យកុមារ ផ្តោតអារម្មណ៍ បង្កើនការស្រមើស្រមៃ ការច្នៃប្រឌិត ស្គាល់ប្រភេទវត្ថុ ចំណេះដឹងអំពីជីវិតរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ មានបទពិសោធ មានបំណិនទំនាក់ទំនងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ស្រឡាញ់សន្តិភាព និងមានភាពសុខដុមរមនាក្នុងគ្រួសារ និងសង្គម។ ទន្ទឹមនឹងនេះ ការអានសៀវភៅរូបភាព ជួយឱ្យកុមារអភិវឌ្ឍភាសា ចេះប្រើវោហារសព្ទសម្បូរបែប និងចាប់ផ្តើមមានអារម្មណ៍ចូលចិត្ត បង្កើនភាពស្និទ្ធស្នាល យល់ចិត្តគ្នា បញ្ចេញយោបល់ ផ្តល់សេចក្តីស្រឡាញ់ និងមានទំនុកចិត្តលើអ្នកនិទាន។

កម្មវិធីសិក្សាថ្មីក៏បានចែងពីភាពចាំបាច់ ដែលធ្វើឱ្យកុមាររីករាយជាមួយនឹងការនិទានរឿង ការរៀបចំសកម្មភាពផ្សេងៗ ធ្វើឱ្យកុមារចូលរួមដោយពេញចិត្ត និងសប្បាយរីករាយ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បន្តការសិក្សាពេញមួយជីវិត។

Scanned with MOBILE SCANNER

# ជំពូកទី១
## រឿងនិទាន




Scanned with MOBILE SCANNER

**ការនិទានរឿងពង្រឹងទំនាក់ទំនង**

- មានភាពកក់ក្តៅ
- ការជឿជាក់
- សុវត្ថិភាព
- ស្រលាញ់ចូលចិត្ត





- រីករាយ!
- អារម្មណ៍ធូរស្រាល
- ចែករំលែកបទពិសោធពីគ្នា

- សប្បាយ ចែករំលែកអារម្មណ៍ផ្សេងៗ



ការនិទានរឿងបង្កើតឱ្យមានទំនាក់ទំនង ការចែករំលែកក្តីស្រឡាញ់ ភាពសប្បាយរីករាយ ការស្រមើស្រមៃ ការទទួលបទពិសោធ និងសេចក្តីសុខទាំងអស់គ្នា។

ជាតិសាសន៍នីមួយៗមានការនិទានរឿងច្រើនបែប ច្រើនសណ្ឋាន ក្នុងគោលបំណងផ្សព្វផ្សាយនូវវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ សាសនា ចំណេះដឹង និងគោលគំនិតផ្សេងៗរបស់ដូនតារៀងៗខ្លួន។ រឿងនិទាននៅមត្តេយ្យសិក្សាចែកចេញជាពីរគឺការនិទានរឿង និងការបង្រៀនរឿងនិទាន។

## ១. ការនិទានរឿង និងការបង្រៀនរឿងនិទាន

### ១.១. ការនិទានរឿង

ការនិទានរឿងជាការនិយាយរឿងរ៉ាវតៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដែលបានចេះចាំប្រាប់ដល់អ្នកស្តាប់។

ការនិទានរឿងបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងគ្រឹះស្ថានមត្តេយ្យសិក្សា ព្រោះបានផ្តល់ភាពសុខសាន្ត សប្បាយដល់កុមារ ការរីកចម្រើនថាមពលនៃការគិត បង្កើនការស្រមើស្រមៃ និងភាពជាម្ចាស់។






### ១.២. ការបង្រៀនរឿងនិទាន

ការបង្រៀនរឿងនិទាន គឺជាការនិទានរឿងនៅក្នុងម៉ោងសិក្សា ដែលជួយកុមារឱ្យយល់ពីអត្ថន័យនៃខ្លឹមសាររឿង និងមានមូលដ្ឋានគ្រឹះក្នុងការរៃភាគតួអង្គសម្រាប់ជាទុនដល់ការរិះគិតបែងចែកល្អ និងអាក្រក់តាមរយៈការអនុវត្តវិធីប្រើប្រាស់សំណួរ ឬផ្សារភ្ជាប់នឹងសកម្មភាពគោលមានដូចជា ល្បែង ចម្រៀង សកម្មភាពកសាង គំនូរជាដើម...។

## ២. សារៈសំខាន់ និងប្រសិទ្ធភាពរឿងនិទាន










រឿងនិទានគឺជាវិធីមួយដែលបម្រើឱ្យការលេង «ការលេងគឺជាការរៀនរបស់កុមារតូច»។ ដូច្នេះ យើងគម្បីពិចារណាលើការផ្តល់នូវភាពសប្បាយរីករាយដល់កុមារក្នុងពេលនិទានរឿងនៅពេលកំណត់វត្ថុបំណងសកម្មភាព។ ខាងក្រោមជាសារៈសំខាន់ និងប្រសិទ្ធភាពមួយចំនួនដល់ការអភិវឌ្ឍរបស់កុមារនៅពេលស្តាប់រឿងនិទាន៖

- ការចែករំលែកអារម្មណ៍សប្បាយរីករាយ កក់ក្តៅជាមួយគ្រូ មិត្តភក្តិ ពេលស្តាប់រឿងនិទាន។ វាជាពេលវេលាអ្នកនិទាន និងអ្នកស្តាប់បានផ្តល់ឱ្យគ្នាទៅវិញទៅមក។ កុមារនឹងចូលរួមស្តាប់ការនិទានដោយយកចិត្តទុកដាក់ប្រសិនគេមានអារម្មណ៍ថាគ្រូ ឬអ្នកនិទានកំពុងតែផ្តល់នូវភាពជិតស្និទ្ធ និងក្តីស្រលាញ់ដល់គេ។
- ពេលអានសៀវភៅរូបភាព នាំឱ្យកុមារចូលចិត្តស្រឡាញ់ការអានសៀវភៅ។ ជារឿយៗ ពេលស្តាប់រឿងនិទានចប់ គេនៅមានអារម្មណ៍ជិតជាមនឹងសាច់រឿង តួអង្គ ឬរូបភាពក្នុងសៀវភៅ ដូច្នេះ គេចង់ទៅស្វែងរកមើលសៀវភៅបន្ថែមនៅជ្រុងសិក្សា ឬបណ្ណាល័យ។
- ការទទួលបានអារម្មណ៍ខុសប្លែកពីគ្នា ដូចជាអារម្មណ៍ភ្ញាក់ផ្អើល រីករាយ ទុក្ខសោក អាណិតអាសូរ ឬអារម្មណ៍លំហែជាដើម។ យើងអាចសង្កេតឃើញនូវចំណុចទាំងអស់តាមរយៈទឹកមុខ ពាក្យសម្តី ដដែកឆ្លើយឆ្លងរបស់កុមារ ដូចជា «គួរឱ្យអាណិតប្អូនទន្សាយណាស់» ជាដើម។
- ការអភិវឌ្ឍការគិតបែបវិជ្ជមាន និងចង់ឱ្យខ្លួនឯងជាមនុស្សល្អដូចតួអង្គក្នុងសាច់រឿង។ ជាទូទៅសៀវភៅរឿងសម្រាប់កុមារច្រើនមានខ្លឹមសារអប់រំឱ្យដើរក្នុងផ្លូវល្អ និងមានឥរិយាបទវិជ្ជមាន។ កុមារស្វែងយល់ថានៅពេលខ្លួនធ្វើល្អ គេនឹងទទួលបានការស្រលាញ់ និងសរសើរពីអ្នកដទៃ។ យើងតែងតែសង្កេតឃើញកុមារនិយាយថា«ខ្ញុំចង់ពូកែដូចគាត់ដែរ» «ខ្ញុំចង់ក្លាយជាមនុស្សល្អបែបនេះណាស់»។
- មានបទពិសោធក្នុងបរិស្ថានធម្មជាតិ សង្គមមនុស្ស និងរូបារម្មណ៍ច្នៃប្រឌិតដែលបានមកពីការស្រមើស្រមៃនៃពិភពរឿងនិទាន។ នៅពេលគេឃើញតួអង្គមានទុក្ខសោក គាត់ចាប់ផ្តើមគិតក្នុងចិត្តថា «ហេតុអ្វីបានជាគាត់យំ? ប្រហែលជាគាត់ឃ្លានអាហារទេដឹង!»
- ការរីកចម្រើនសមត្ថភាពអាន ពាក្យពេចន៍ និងការបញ្ចេញយោបល់ ពីរឿងដែលខ្លួនបានស្តាប់ ដូច្នេះធ្វើឱ្យការទំនាក់ទំនងប្រចាំថ្ងៃកាន់តែមានភាពសម្បូរបែប។ កុមារតូចភាគច្រើនមិនទាន់ចេះអានអក្សរនោះទេ តែហេតុអ្វីបានជាមានកុមារខ្លះចាប់សៀវភៅរឿង បើកមើលរូបភាព តែគេបង្កើតបានជាពាក្យសម្តីផ្សេងៗ តាមសាច់រឿង។ នេះដោយសារគេបានឮ និងចងចាំសម្តីទាំងនោះពីការនិទានរឿងរបស់គ្រូ ឬមនុស្សជុំវិញខ្លួន។



Scanned with
MOBILE SCANNER

## ឧទាហរណ៍ប្រសិទ្ធភាពនៃរឿងនិទានក្នុងការអភិវឌ្ឍវិស័យទាំង៥

| | |
|---|---|
| ការអភិវឌ្ឍរូបរាងកាយ និងសុខភាព  | • កុមាររៀនពីរបៀបធ្វើចលនាដៃ និងម្រាមដៃដើម្បីបើកទំព័រសៀវភៅ<br>• កុមារមានទម្លាប់ល្អក្នុងការចោលសំរាម ទម្លាប់ប្រើប្រាស់បង្គន់អនាម័យ ទឹកស្អាត និងមានអនាម័យខ្លួនប្រាណ<br>• កុមារមានចំណេះដឹងអំពីក្រុមអាហារ និងអាហារូបត្ថម្ភ។ |
| ការអភិវឌ្ឍសីលធម៌ និងវប្បធម៌  | • កុមារស្គាល់ និងរក្សាអត្តសញ្ញាណជាតិរបស់ខ្លួនបានខ្ជាប់ខ្ជួន<br>• កុមារចេះប្រតិបត្តិទំនៀមទម្លាប់ ប្រពៃណី និងសាសនារបស់ខ្លួន ឬសាសនាផ្សេងៗ<br>• កុមារយល់ដឹងពីរបៀបរបបរស់នៅរបស់ប្រទេសផ្សេងៗក្នុងពិភពលោក<br>• កុមារគោរពគ្នាទៅវិញទៅមក ជម្រាបសួរ អរគុណ សូមទោសមានអធ្យាស្រ័យគ្នា និងប្រកបដោយបរិយាបន្ន។ |
| ការអភិវឌ្ឍសង្គម និងអារម្មណ៍  | • កុមារអភិវឌ្ឍចិត្តសង្គម ដោយមិនប្រើអំពើហិង្សាទាំងរាងកាយ និងផ្លូវចិត្ត<br>• កុមារមានទំនាក់ទំនងល្អក្នុងជីវភាពរស់នៅប្រចាំថ្ងៃ<br>• កុមារសហការគ្នា និងមានអាកប្បកិរិយាបែបវិជ្ជមានទៅកាន់អ្នកដទៃ<br>• កុមារស្គាល់ពីអារម្មណ៍ ចេះសម្តែងអារម្មណ៍ និងគ្រប់គ្រងអារម្មណ៍ខ្លួនឯង។ |
| ការអភិវឌ្ឍការយល់ដឹង និងការពិចារណា  | • កុមារយល់ពីហេតុ និងផល<br>• កុមារសម្រេចចិត្តដោយការទទួលខុសត្រូវ<br>• កុមារយល់ដឹងពីការប្រតិបត្តិខ្លួន ដើម្បីសុខសុវត្ថិភាព<br>• កុមាររៀនរស់នៅដោយឯករាជ្យ និងភាពជាម្ចាស់ការលើខ្លួនឯង<br>• កុមារយល់ដឹងពីបរិស្ថាន វប្បធម៌ និងសង្គម<br>• កុមារអភិវឌ្ឍសមត្ថភាពនៃការគិត រូបរាង លំហ ទំហំ ពណ៌ បរិមាណ និងចំនួន រង្វាស់រង្វាល់។ |
| ការអភិវឌ្ឍភាសា  | • កុមារមានទម្លាប់ក្នុងការអាន និងការប្រើប្រាស់សៀវភៅ<br>• កុមារចេះប្រើវាក្យសព្ទ ឃ្លាប្រយោគបានត្រឹមត្រូវ ដើម្បីទំនាក់ទំនងក្នុងសង្គម<br>• កុមារមានសមត្ថភាពអភិវឌ្ឍបំណិនទាំង៦(ពិនិត្យសង្កេត ស្តាប់ ចលនា ភាសា លំហ និងពេលវេលា)<br>• កុមារចាប់ផ្តើមចាប់អារម្មណ៍លើតួអក្សរ។ |









# ជំពូកទី២
# ការអនុវត្តការនិទានរឿង

Scanned with MOBILE SCANNER

ការនិទានរឿងមានសារៈសំខាន់ និងមានអត្ថប្រយោជន៍ចំពោះកុមារ ព្រោះជួយឱ្យកុមារស្វែងយល់ រុករក ស្រាវជ្រាវតាមរយៈសាច់រឿង។ ការនិទានរឿងប្រកបដោយភាពទាក់ទាញធ្វើឱ្យកុមារចង់តាមដានសាច់រឿងយ៉ាងជក់ចិត្តរហូតដល់ចប់។ យើងអាចអនុវត្តន៍បាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដូចជានៅផ្ទះ នៅសាលារៀន ពេលចេញលេង ឬក្នុងម៉ោងសិក្សាជាដើម។

## ១. មូលដ្ឋានគ្រឹះនៃការនិទានរឿង

រឿងនិទានគឺជាវិធីអប់រំមួយប្រកបដោយចិត្តសាស្ត្រ (ដោយប្រយោល) រួមទាំងការបង្កើតបរិយាកាសសប្បាយរីករាយ និងធ្វើឱ្យអ្នកស្តាប់មានចិត្តស្រស់ថ្លាមានអារម្មណ៍ធូរស្រាល ពីភាពនឿយហត់។ ដូច្នេះការនិទានរឿងទាមទារឱ្យគ្រូមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានវត្ថុបំណងច្បាស់លាស់ ក្នុងការជ្រើសរើសរឿងនិទាន ការរៀបចំទីកន្លែង សម្ភារ និងពេលវេលា។

### ១.១. វត្ថុបំណងនៃការនិទានរឿង

**រឿងនិទានសម្រាប់កុមារមានវត្ថុបំណងឱ្យអ្នកស្តាប់ និងអ្នកអាន៖**

- **មានចិត្តរីកបសប្បាយរីករាយ អារម្មណ៍ភ្លឺថ្លាស្រស់ស្រាយ ធូរស្រាលពីភាពស្មុគស្មាញ ចូលចិត្តស្តាប់ និងអានរឿងនិទាន**
- **អភិវឌ្ឍការស្រមើស្រមៃ ភាសា មានគំនិតច្នៃប្រឌិត ការគិតពិចារណាបានគ្រប់ជ្រុងជ្រោយ ទទួលបានការអប់រំ និងសីលធម៌ល្អ**
- **ផ្តល់ឱកាសឱ្យកុមារបានទាយទុកមុននូវព្រឹត្តិការណ៍ និងសកម្មភាពតួអង្គ ដែលនឹងកើតមានឡើង**
- **បណ្តុះទម្លាប់ក្នុងការអានដល់កុមារតូច។**

### ១.២. លក្ខណៈសម្បត្តិគ្រូ

- **ការរៀបចំខ្លួនឱ្យបានសមរម្យ**
- **ការនិទានរឿងនៅ**ទីកន្លែងសមស្រប និងមានសុវត្ថិភាព
- **ការចេះចាំសាច់រឿង និងនិទានឱ្យត្រូវតាមខ្លឹមសារសាច់រឿង**
- **ការប្រើវិធីសាស្ត្រសម្បូរបែបក្នុងដំណើរការនិទានរឿង**
- **ការនិទានត្រូវដាក់អារម្មណ៍ទៅក្នុងសាច់រឿង និងទាក់ទាញចំណាប់អារម្មណ៍របស់កុមារ**
- **ការយកចិត្តទុកដាក់ចំពោះប្រតិកម្មរបស់កុមារ**
- **ការប្រើពាក្យពេចន៍និទានឱ្យខ្លី សាមញ្ញ ដើម្បីឱ្យកុមារងាយយល់ពាក្យ និងខ្លឹមសាររឿង**
- **ការស្រាវជ្រាវ និងអនុវត្តន៍ការនិទានរឿងឱ្យបានស្ទាត់ជំនាញ**
- **ការធ្វើអន្តរកម្មជាមួយកុមារក្នុងពេលនិទាន។**



### ១.៣. ការត្រៀមលក្ខណៈរបស់គ្រូ

**ក. ការជ្រើសរើសរឿងនិទាន**

ការជ្រើសរើសរឿងជាការងារចាំបាច់ និងមានអត្ថប្រយោជន៍ ដើម្បីឱ្យកុមារស្លុងអារម្មណ៍ ទៅនឹងសាច់រឿង ដែលគ្រូយកមកនិទានឱ្យកុមារស្តាប់៖

- ខ្លឹមសាររឿងសមស្របតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ ឬរឿងខ្លី ដោយមិនមានតួអង្គច្រើនពេក
- មានខ្លឹមសារអប់រំ ឈ្មោះខ្លីៗ ពាក្យងាយស្តាប់ និងឆាប់យល់
- សៀវភៅរឿងដែលមានអក្សរធំអាចឱ្យកុមារមើលច្បាស់គឺកាន់តែប្រសើរ
- រូបគំនូរ និងអត្ថបទបំពេញឱ្យគ្នាទៅវិញទៅមក ហើយចំណងជើងរឿងស៊ីនឹងខ្លឹមសាររឿង
- រយៈពេលនៃការនិទានរឿងសមស្រប និងបង្កប់នូវខ្លឹមសារអប់រំ
- ជ្រើសរើសរឿងតាមសំណូមពររបស់កុមារតាមកាលៈទេសៈជាក់ស្តែង
- គ្រូអាចប្រឌិតរឿងខ្លីៗទៅតាមស្ថានភាពជាក់ស្តែង ដើម្បីគាំទ្រការបង្រៀន និងការរៀនតាមមុខវិជ្ជានីមួយៗ
- ខ្លឹមសាររឿងតាមរដូវកាល ទីកន្លែង និងព្រឹត្តិការណ៍ផ្សេងៗ។

**ខ. ការរៀបចំទីកន្លែង**

ការរៀបចំបរិស្ថានសិក្សាត្រូវផ្តោតលើកុមារជាកត្តាសំខាន់ ដោយធ្វើឱ្យកុមារចាប់អារម្មណ៍ និងរីករាយក្នុងការស្តាប់រឿងនិទាន។ ដូច្នេះ អ្នកនិទានត្រូវយកចិត្តទុកដាក់ជាពិសេសដូចខាងក្រោម៖

- **ក្នុងថ្នាក់រៀន**
  - ត្រូវបើកទ្វារ បង្អួចឱ្យមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់
  - រៀបចំសិស្សឱ្យអង្គុយតាមស្ថានភាពជាក់ស្តែង(តុ កៅអី ឬកន្ទេល...)
- **ក្រៅថ្នាក់រៀន**
  - ពិនិត្យទីធ្លា និងរៀបចំឱ្យបានត្រឹមត្រូវមុននឹងនិទានរឿង ដោយមិនមានសំឡេងរំខានច្រើនពេក
  - ទីកន្លែងមានសុវត្ថិភាពដល់កុមារមិនមានបន្លា មែកឈើធ្លាក់ និងវត្ថុមុតស្រួច ដែលអាចគ្រោះថ្នាក់ដល់កុមារ
  - រៀបចំកន្លែងអង្គុយនៅក្រោមម្លប់ឈើ ឬកន្លែងណាដែលសមរម្យឱ្យកុមារអង្គុយបាន
  - រៀបចំកុមារឱ្យបានសមស្របតាមវ័យ និងអង្គុយបែរខ្នងទៅពន្លឺថ្ងៃ ដើម្បីកុំឱ្យចាំងភ្នែកកុមារ។

Scanned with MOBILE SCANNER



ការនិទានរឿងនៅក្រៅថ្នាក់រៀន



ការនិទានរឿងនៅក្នុងថ្នាក់រៀនដោយឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ (U)




គម្លាតសមស្របរវាងអ្នកនិទាន និងអ្នកស្ដាប់



## ២. ដំណើរការនិទានរឿង

**គ្រូត្រូវរៀបចំកន្លែងអង្គុយឱ្យបានសមស្រប និងយកចិត្តទុកដាក់ចំពោះកុមារប្រកបដោយបរិយាបន្ន (ខ្សោយបញ្ញា ស្ដាប់ មើល ជាតិសាសន៍នានា វណ្ណៈ ពណ៌សម្បុរ...)។**

### ២.១. ការរៀបចំកុមារ និងសម្ភារ

- រៀបចំកុមារអង្គុយឱ្យបានសមស្រប(អង្គុយលើកៅអី កម្រាល ឥដ្ឋការ៉ូ កៅស៊ូ កន្ទេល ឬស្បែកជើង)
- ការបង្ហាញរូបភាពរឿងនិទានទាំងនោះឱ្យត្រង់ចំកណ្ដាលពីមុខកុមារ មិនផ្អៀង និងមិនបាំងរូបភាព
- រៀបចំកុមារអង្គុយមើលរូបភាពឱ្យបានច្បាស់(មិនខ្ពស់ពេក មិនទាបពេក)
- រៀបកុមារឱ្យអង្គុយតាមលំដាប់ពីទាបទៅខ្ពស់ ពីមុខទៅក្រោយដែលអាចមើលឃើញរូបភាពគ្រប់គ្នា
- រៀបចំសម្ភារ និងល្បែងដែលត្រូវត្រៀមទៅតាមប្រភេទរឿងនិទាន។

### ២.២. ល្បែងទាញអារម្មណ៍

**ល្បែងទាញអារម្មណ៍ជាល្បែង ឬសកម្មភាពប្រើប្រាស់ដើម្បីនាំកុមារចូលក្នុងការនិទានរឿង។ គោលបំណងសំខាន់គឺប្រមូលនូវការផ្ចង់អារម្មណ៍ និងការត្រៀមខ្លួនរបស់កុមារ។ ជាទូទៅ នៅពេលដែលគ្រូរៀបនឹងចាប់ផ្ដើមនិទានរឿង កុមារមួយចំនួនមិនទាន់ផ្ដោតអារម្មណ៍នៅឡើយ ដោយគេបន្តជជែកគ្នា ចង់ប្ដូរទីកន្លែងអង្គុយ និងខ្លះនៅមានចំណីនៅនឹងដៃជាដើម។ ទន្ទឹមនឹងនោះដែរ កុមារមួយចំនួនអាចនៅមានអារម្មណ៍អស់កម្លាំង ឬងងុយគេងបន្ទាប់ពីធ្វើសកម្មភាពមុនៗ ដូច្នេះការលេងល្បែងទាញអារម្មណ៍ធ្វើឱ្យគ្រូអាចប្រមូលផ្ដុំការយកចិត្តទុកដាក់ បម្រុងប្រយ័ត្ន និងថាមពលរបស់កុមារមកលើការនិទានរឿង។ ល្បែងទាញអារម្មណ៍ជាមធ្យមមានរយៈពេល១ទៅ៣នាទី។ គ្រូអាចជ្រើសរើសសកម្មភាពណាមួយដូចខាងក្រោម៖**

- សំណេះសំណាលជាមួយកុមារ
- ប្រើជាសំណួរ(ទាយរូបភាព)
- ចម្រៀងកាយវិការ
- លេងល្បែង
- ពាក្យបណ្ដៅ។

### ២.៣. និទានរឿង

ដើម្បីឱ្យការនិទានមានភាពរហូន អ្នកនិទានរឿងត្រូវអនុវត្តន៍ដូចខាងក្រោមនេះ៖

- ឈរ ឬអង្គុយឱ្យបានសមរម្យ
- ធ្វើយ៉ាងណាឱ្យកុមារទាំងអស់ស្ដាប់ និងមើលឃើញរូបភាពបានច្បាស់
- ប្រាប់ ឬទាយចំណងជើងរឿង(មុន ឬក្រោយ)
- ប្រើប្រាស់ពាក្យពេចន៍សាមញ្ញងាយយល់
- ប្រើសំឡេងធម្មជាតិ ប្រើទឹកមុខ កាយវិការ និងលើកដាក់សំឡេងតាមតួអង្គនៃសាច់រឿង
- ទុកឱកាសឱ្យកុមារបង្កើតរូបារម្មណ៍
- សង្កេតប្រតិកម្មកុមារក្នុងពេលនិទាន

Scanned with MOBILE SCANNER

- ករណីដែលកុមារមិនសូវយកចិត្តទុកដាក់ស្តាប់រឿង គ្រូត្រូវផ្លាស់ប្តូរវិធីសាស្ត្រ និងរបៀបផ្សេងៗទៀត ដែលទាក់ទងនឹងខ្លឹមសាររឿង ដោយមិនបង្ខំកុមារ។

### ២.៤. ក្រោយពេលនិទានរឿង

- ចុងបញ្ចប់នៃរឿងនិទាន និយាយទៅកាន់កុមារដើម្បីបញ្ចប់រឿងជាមួយស្នាមញញឹម និងក្តីស្រឡាញ់។ អ្នកអាចឱ្យដំបូន្មាន សុភាសិត ឬគតិរឿង ប៉ុន្តែពេលខ្លះក៏មិនចាំបាច់ដែរ វាអាស្រ័យទៅតាមកាលៈទេសៈ។
- វាយតម្លៃការនិទានរឿងដោយខ្លួនឯង ហើយដកស្រង់នូវបទពិសោធនេះសម្រាប់កែលម្អនៅពេលក្រោយ
  - មិនត្រូវសួរកុមារថាតើការនិទានរឿងនេះល្អដែរ ឬទេ?
  - តាមរយៈសកម្មភាព ទឹកមុខ ក្រសែភ្នែករបស់ពួកគេយើងអាចដឹងបានថាពួកគេចូលចិត្តការនិទានរឿង ឬមិនចូលចិត្ត?
  - ប្រតិកម្មរបស់កុមារគឺជារង្វាយតម្លៃថាតើការនិទានរឿងល្អ ឬមិនសូវល្អ?
  - ចំពោះការបង្រៀនរឿងនិទានគ្រូត្រូវចោទសួរចំណងជើង តួអង្គ និងវិភាគតួអង្គ។

## ៣. គន្លឹះទាញអារម្មណ៍កុមារឱ្យចូលចិត្តស្តាប់រឿងនិទាន

ក្នុងពេលនិទានរឿង យើងតែងតែសង្កេតឃើញមានកុមារខ្លះមិនចាប់អារម្មណ៍ ដូច្នេះការនិទានរឿងពុំអាចទទួលបានតាមលទ្ធផលរំពឹងទុក។ ខាងក្រោមនេះជាគន្លឹះខ្លះដែលអ្នកនិទានធ្លាប់ប្រើប្រាស់៖

- ប្រសិនបើកុមារមិនសូវស្តាប់ អ្នកនិទានរឿងត្រូវប្តូរល្បិច ឬវិធីភ្លាមៗ( ឧ៖ គ្រូត្រូវប្តូរសំឡេងផ្សេងៗ ឬធ្វើកាយវិការផ្សេងៗ មើលចំមុខកុមារ ដើម្បីទាញអារម្មណ៍កុមារត្រឡប់មកវិញ )
- អំឡុងពេលនិទានមានកុមារមិនសូវចាប់អារម្មណ៍ គ្រូត្រូវអនុវត្តន៍នូវចំណុចដូចខាងក្រោម៖
  - ប្រើសំឡេងតួអង្គ ដើម្បីទាញអារម្មណ៍កុមារត្រឡប់មកស្តាប់សាច់រឿងវិញ
  - ប្រើសំឡេងឱ្យឮជាងមុន ឬតិចជាងមុន ដើម្បីទាញអារម្មណ៍កុមារឱ្យវិលមកស្តាប់ការនិទានរឿងវិញ
  - ប្រើក្រសែភ្នែកមើលទៅកាន់កុមារ
- ពេលកំពុងនិទានរឿងមានកុមារក្រោកទៅចង្អុលរូបភាព
  - ប្រើកាយវិការក្នុងសាច់រឿង ដើម្បីឱ្យកុមារទៅអង្គុយនៅកន្លែងដើមវិញ ( ឧ៖ បន្ទាបខ្លួនចុះ )
  - ប្រើដៃជាសញ្ញាឱ្យកុមារទៅកាន់កន្លែងដើម ( ឧ៖ )
  - មានវិធីផ្សេងៗទៀតបត់បែប និងរៀងៗខ្លួនទៅតាមស្ថានភាពជាក់ស្តែងរៀងខ្លួនៗ។

- ពេលកំពុងនិទានរឿងមានកុមារឈ្លោះគ្នា
  - ប្រើពាក្យសម្តីនៅក្នុងសាច់រឿង ដើម្បីឱ្យកុមាររក្សារបៀបរៀបរយឡើងវិញ
  - ពង្រឹងវិន័យកុមារមុនពេលនិទាន
  - ក្នុងករណីកុមារវាយគ្នា ឈ្លោះស្រែកយំខ្លាំង គ្រូគប្បីហៅឈ្មោះកុមារទាំងពីរ ឬផ្អាកការនិទានរឿង ដើម្បីសម្របសម្រួល បន្ទាប់មកបន្តការនិទានរឿងទៀត( ត្រង់ចំណុចនេះ គ្រូគប្បីឆ្លុះបញ្ចាំង និងពិចារណាលើការរៀបចំទីតាំងអង្គុយរបស់កុមារ ការគ្រប់គ្រងកុមារ និងវិធីនិទានរឿង )។
- កុមារបរិយាបន្ន៖ កុមារបរិយាបន្នមានលក្ខណៈផ្សេងៗគ្នា ដែលគ្រូត្រូវពិចារណានៅពេលរៀបចំកុមារអង្គុយពេលនិទានរឿង។ ឧទាហរណ៍ កុមារកំសោយការស្តាប់ ឬការមើល ដូច្នេះក្នុងពេលនិទានរឿង គ្រូត្រូវឱ្យគាត់អង្គុយនៅជួរខាងមុខ។

### បទពិសោធការគ្រប់គ្រងកុមារចូលចិត្តលេងច្រើនក្នុងពេលនិទានរឿង៖

ក្នុងពេលនិទានរឿង មានកុមារម្នាក់តែងតែលេងច្រើនជាមួយកុមារដទៃទៀត ដោយចាក់ចង្កេះ នាំកុមារដទៃនិយាយពីនេះពីនោះ។ គ្រូបានសាកល្បងវិធីច្រើនដែរតែនៅមិនបានផល។ ថ្ងៃមួយគ្រូបាននឹកឃើញវិធីសាមញ្ញមួយ។ គាត់បានរៀបចំកម្រាលអង្គុយពិសេសសម្រាប់កុមារនេះដាក់នៅខាងមុខគេ។ មុនពេលនិទានរឿងគាត់បានប្រាប់ទៅកុមារនោះថា«នេះជាកម្រាលទិព្វរបស់កូន បើកូនអង្គុយលើកម្រាលនេះ កូននឹងស្តាប់ការនិទានរឿងបានយ៉ាងល្អ»។ កុមារយល់ព្រមស្តាប់តាមការណែនាំរបស់គ្រូ ហើយគាត់គិតថាគាត់ទទួលបានការរៀបចំយ៉ាងពិសេស។ ជាលទ្ធផល កុមារនោះមានឥរិយាបថប្រសើរឡើង ព្រមទាំងស្តាប់ការនិទានរឿងដោយយកចិត្តទុកដាក់។

កុមារខ្លះតែងតែសម្តែងនូវប្រតិកម្មភ្លាមៗតាមសាច់រឿង ដូចជាសម្តី កាយវិការ ក្រោកឈរធ្វើសកម្មភាពតាមសាច់រឿង ក្រោកទៅចាប់ ឬចង្អុលរូបភាពក្នុងសៀវភៅ និយាយឆ្លើយឆ្លងជាមួយគ្រូ។ ពេលខ្លះគ្រូក៏មិនចាំបាច់បារម្ភពីសកម្មភាពឆ្លើយតបទាំងនេះពេកទេ ព្រោះវាតែងតែកើតមានឡើងធម្មតា ដូច្នេះយើងអាចបន្តឆ្លុះបញ្ចាំងពីបញ្ហា និងកែលម្អបន្តទៀត។

Scanned with MOBILE SCANNER




# ជំពូកទី៣
# ប្រភេទរឿងនិទាន

ប្រភេទនៃរឿងមានច្រើនប្រភេទតាមការច្នៃប្រឌិត ឬកែច្នៃតាមការយល់ឃើញ ដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកស្តាប់ដែលមានដូចខាងក្រោម៖

១. និទានរឿងដោយផ្ទាល់មាត់
២. និទានរឿងដោយសៀវភៅរូបភាព
៣. និទានរឿងដោយផ្ទាំងរូបភាព
- និទានរឿងដោយផ្ទាំងរូបភាព
- និទានរឿងដោយឧបករណ៍ប្រអប់ទូរទស្សន៍
- និទានរឿងដោយក្តាខៀន ឬផ្ទាំងសំពត់សំឡី

៤. និទានរឿងដោយតុក្កតា ឬអាយ៉ង (តុក្កតា ស្រោមដៃ រូបដោត អាវអៀម)
- និទានរឿងដោយតុក្កតា
- និទានរឿងស្រោមដៃ
- និទានរឿងដោយរូបដោត
- និទានរឿងដោយអាវអៀម

៥. និទានរឿងបណ្តើរ គូរបណ្តើរ
៦. និទានរឿងដោយសម្តែងតួតាមសាច់រឿង (កុមារដើរតួផ្ទាល់)។



ការនិទានដោយប្រអប់ផ្ទាំងរូបភាព





និទានរឿងដោយឧបករណ៍ប្រអប់ទូរទស្សន៍



ឧបករណ៍ប្រអប់ទូរទស្សន៍មើលពីចំហៀង៖ មានដងសម្រាប់បង្វិលដើម្បីឱ្យផ្ទាំងសាច់រឿងមានចលនាពីក្រោមទៅលើ



ឧបករណ៍ប្រអប់ទូរទស្សន៍មើលពីខាងក្រោយ

Scanned with MOBILE SCANNER

## ១. និទានរឿងដោយផ្ទាល់មាត់



និទានរឿងផ្ទាល់មាត់មិនមានតម្រូវឱ្យប្រើប្រាស់សម្ភារអ្វីនោះឡើយ ដោយអ្នកនិទានគ្រាន់តែចាំសាច់រឿង ហើយយកមកនិទាន។ ទោះបីជាយ៉ាងនេះក្តី យើងអាចកែច្នៃការនិទានរឿងឱ្យកាន់តែមានភាពទាក់ទាញ ដូចជាប្រើប្រាស់ឧបករណ៍ភ្លេងជំនួយបានកាន់តែប្រសើរ។ ខាងក្រោមជាគន្លឹះខ្លះជួយដល់ការនិទានរឿងផ្ទាល់មាត់៖

- ចេះចាំសាច់រឿងឱ្យបានច្បាស់លាស់
- យល់ពីខ្លឹមសាររឿង និងដំណើររឿងតាមឈុតឆាកនីមួយៗ
- ធ្វើកាយវិការ និងសំឡេងផ្លាស់ប្តូរទៅតាមតួអង្គនីមួយៗ
- សម្លឹងមើលភ្នែក និងទឹកមុខអ្នកស្តាប់ក្នុងពេលកំពុងនិទាន
- កុំនិយាយបញ្ចេញបញ្ចូលច្រើនពេក
- ពេលខ្លះអាចប្រើឧបករណ៍តន្ត្រី ដូចជាស្គរដើម្បីធ្វើឱ្យបរិយាកាសកាន់តែមានភាពរីករាយ។






និទានផ្ទាល់មាត់ រឿងទន្សាយចង់ស៊ីចេក



និទានរឿងផ្ទាល់មាត់ មានប្រើប្រាស់ឧបករណ៍តន្ត្រីជំនួយជាគំនិតល្អមួយ

Scanned with MOBILE SCANNER

## ២. និទានរឿងដោយសៀវភៅរូបភាព




និទានរឿងដោយសៀវភៅរូបភាពគឺជាការបរិយាយសាច់រឿងទៅតាមរូបភាពក្នុងសៀវភៅឱ្យកុមារស្ដាប់ពីមួយទំព័រទៅមួយទំព័រទៀត។ គុណសម្បត្តិនៃការនិទានរឿងដោយសៀវភៅរូបភាពគឺធ្វើឱ្យកុមារចាប់អារម្មណ៍ទៅលើការមើល ឬអានសៀវភៅរូបភាព។

### ១. របៀបនិទានរឿង

- ត្រូវហ្វឹកហាត់បើកសៀវភៅរូបភាពដោយប្រើម្រាមដៃបើកម្ដងមួយសន្លឹកៗ
- ជ្រើសរើសឥរិយាបថនិទានតាមស្ថានភាពជាក់ស្ដែង(អង្គុយ ឈរ អង្គុយលើកៅអីទាបឬខ្ពស់ លើឆាក ជាដើម) និងមានភាពងាយស្រួលសម្រាប់អ្នកនិទាន ដូចមានបង្ហាញនៅទំព័របន្ទាប់
- ពេលនិទានកាន់សៀវភៅឲ្យចរិមខាងក្រោម ឬលើកុំឱ្យបាំងរូបភាព
- ចំពោះខ្លឹមសាររឿងនៅទំព័របន្ទាប់ខ្លះ អ្នកនិទានបើកទំព័រយឺតៗ ដោយពោលពាក្យថា «រំពេចនោះ ឬស្រាប់តែ ឬធ្វើជាសំឡេងតួអង្គដែលត្រូវបង្ហាញខ្លួន ដើម្បីទុកឱកាស និងទាក់ទាញឱ្យកុមារអ្នកស្ដាប់បានគិត បានបង្កើតក្ដីស្រមៃ ទាយទុកមុននូវព្រឹត្តិការណ៍រឿងដែលនឹងកើតមានឡើងនៅទំព័របន្ទាប់នោះ»
- កាយវិការឈរ ឬអង្គុយមួយកន្លែងកម្រើកសៀវភៅឡើងលើ ចុះក្រោម ទៅមុខ ថយក្រោយ តម្រូវតាមសកម្មភាពតួអង្គ រួចរក្សាលំនឹង។



### ២.គន្លឹះកាន់សៀវភៅ

#### និទានឈរ



ដាក់សៀវភៅនៅពាក់កណ្ដាលដងខ្លួន
- ដៃម្ខាងកាន់ទ្រ ដៃម្ខាងបើកសៀវភៅ ឬ
- ដៃទាំងពីរកាន់ទ្រសៀវភៅខាងក្រោម ដោយប្រើម្រាមដៃបើកទំព័រសៀវភៅ។

#### និទានអង្គុយ



របៀបនិទានអង្គុយកាន់សៀវភៅដូចឈរដែរ ឬ
- ដាក់សៀវភៅលើភ្លៅ ដៃម្ខាងកាន់ពីលើ ដៃម្ខាងបើកទំព័រ ដោយមិនបាំងរូបភាព ។

#### អង្គុយនិទានដាក់សៀវភៅទៅចំហៀង



- កាន់សៀវភៅនៅចំហៀងខាងឆ្វេង ឬស្ដាំ អាស្រ័យលើភាពប៉ិនប្រសប់
- ដៃម្ខាងនៅទ្រសៀវភៅ ដៃម្ខាងទៀតបើកទំព័រ ធ្វើយ៉ាងណាកុំឱ្យបាំងរូបភាព។

Scanned with MOBILE SCANNER

## ៣. និទានរឿងដោយផ្ទាំងរូបភាព



និទានរឿងដោយប្រើផ្ទាំងរូបភាព(កាំមីស៊ីបៃ) គឺស្រដៀងគ្នានឹងការនិទានរឿងដោយសៀវភៅរូបភាពដែរ គ្រាន់តែសន្លឹកនីមួយៗដាច់ចេញពីគ្នា មានរូបភាពធំៗ ច្បាស់ល្អងាយស្រួលមើល និងមានអក្សរនៅផ្នែកខាងក្រោយ។ យើងក៏អាចនិទានដោយប្រើប្រអប់ផ្ទាំងរូបភាពដាក់លើតុ ងាយកាន់អូស កម្រើកផ្ទាំងរូបភាពក្នុងពេលនិទាន។

### ១. សម្ភារឧបទេស








បច្ចុប្បន្ននេះ យើងសង្កេតឃើញថាការបោះពុម្ពផ្ទាំងរូបភាពមានបរិមាណតិចតួច ហើយពិបាករកទិញក្នុងទីផ្សារ ដូច្នេះ អ្នកនិទានត្រូវផលិតផ្ទាំងរូបភាពដោយខ្លួនឯង។ ជ្រើសរើសរឿងដែលមានចំនួនក្រោម១២សន្លឹកក្នុងមួយរឿង (អាចដាក់រូបពីរឈុតក្នុងមួយសន្លឹកក៏បាន)។

- កាត់ក្រដាសទៅជារាងចតុកោណកែង ទទឹង៣៦សង់ទីម៉ែត្រ និងបណ្ដោយ៥០សង់ទីម៉ែត្រ(គ្រូអាចបត់បែនតាមទំហំក្រដាសដែលមាន)។
- ថតចម្លងសខ្មៅ ឬពណ៌ ឬគូរចម្លងរូបចេញពីក្នុងសៀវភៅ ឬគូររូបដែលច្នៃប្រឌិតរបស់អ្នកនិទាន(រូបភាពតិច ឬច្រើនអាស្រ័យតាមសាច់រឿង)។
- ផាត់ពណ៌លើរូបទាំងអស់។



- នៅខាងក្រោយផ្ទាំងរូបភាពនីមួយៗ អាចសរសេរជាសាច់រឿងបាន តាមលំនាំដូចបង្ហាញខាងក្រោម៖

<u>ឧទាហរណ៍ករណីផ្ទាំងរូបភាពមាន៤សន្លឹក៖</u>




ផ្ទាំងរូបភាព៤សន្លឹកតម្រៀបលើគ្នា មើលពីចំហៀង




ផ្ទាំងរូបភាព៤សន្លឹកតម្រៀបតគ្នា មើលពីមុខ និងក្រោយ

បញ្ជាក់៖ ករណីអ្នកនិទានចាំសាច់រឿងច្បាស់ នៅខាងក្រោយផ្ទាំងរូបភាពមិនចាំបាច់មានសរសេរអក្សរក៏បានដែរ។

### ២. របៀបនិទានរឿង



- រៀបចំទំព័រតាមលំដាប់ជាមុនសិន ដោយផ្កាប់រូបភាពចុះក្រោម
- អង្គុយដាក់ផ្ទាំងរូបភាពលើភ្លៅ ឬឈរកាន់ទ្រូរូបភាពដោយទប់នឹងដងខ្លួន ឬនិទានដាក់ផ្ទាំងរូបភាពលើតុក៏បានដែរ
- ទាញទំព័រពីឆ្វេងទៅស្ដាំ ឬពីស្ដាំទៅឆ្វេងតាមទិសចលនាតួអង្គរូបដាក់នៅផ្នែកខាងក្រោយតាមលំដាប់ ម្ដងមួយផ្ទាំងៗ
- ដើម្បីឱ្យការនិទានរឿងដោយផ្ទាំងរូបភាពកាន់តែទាក់ទាញត្រូវ៖
  - កម្រើកតិចៗ យឺតៗ ឬលឿនទៅតាមសកម្មភាពរបស់តួអង្គ (ដើរយឺតៗ លោតទៅមុខ ដើរលឿន)
  - ហូតផ្ទាំងរូបភាពលឿន ឬយឺតអាស្រ័យទៅតាមសាច់រឿង
  - ហូតតែពាក់កណ្ដាលសន្លឹកទៅតាមរូបភាព។ ឧទាហរណ៍៖ក្នុងករណីរូបភាពមានពីរឈុតត្រូវបង្ហាញម្ដងមួយឈុត។



និទានឈរកាន់ផ្ទាំងរូបភាព



និទានដាក់ផ្ទាំងរូបភាពលើតុ



និទានដាក់ផ្ទាំងរូបភាពលើភ្លៅ

Scanned with MOBILE SCANNER

## និទានរឿងដោយក្តារខៀន ឬផ្ទាំងកំណាត់សំឡី



និទានរឿងដោយរូបបិទគឺជាការនិទានរឿងដោយប្រើប្រាស់ក្តារខៀន និងរូបសម្រាប់បិទ។ អ្នកនិទានត្រូវនិទានបណ្តើរ បិទរូបបណ្តើរ បន្តបន្ទាប់តាមឈុតឆាកនៃខ្លឹមសាររឿងពីដើមដល់ចប់។ ការនិទានបែបនេះគឺជាសកម្មភាពមួយនៃការផ្លាស់ប្តូរប្រភេទនៃការនិទានរឿងដែលធ្វើឱ្យកុមារមានការចាប់អារម្មណ៍ និងចង់ចូលរួមជាមួយការនិទានរឿងរបស់គ្រូបន្ថែមទៀត។ រឿងដែលជ្រើសរើសយកមកមិនគួរមានឈុតឆាក និងតួអង្គច្រើនពេកទេ។

### ១. សម្ភារឧបទេស

ក. ក្តារពាស៖ មានសណ្ឋានស្រដៀងនឹងក្តារខៀនធម្មតា ដោយមានបិទកំណាត់សំឡីសម្រាប់បិទរូបពីលើ។ ការផលិតក្តារពាសមានច្រើនបែប ច្រើនសណ្ឋានតាមការច្នៃប្រឌិតរបស់អ្នកផលិត។ ខាងក្រោមជាឧទាហរណ៍ផលិតពីក្តារកុងប្លាកេ។







- ក្តារពាសមានរាងចតុកោណមានទំហំស្មើ ឬធំជាងក្រដាសA២ (៨០សម x ៥៥សម)។ បិទកំណាត់សំឡីពណ៌ខ្មៅ ប្រផេះ ឬទឹកប៊ិកលើក្តារឱ្យមានសណ្ឋានរាបស្មើល្អ។
- ផលិតចន្ទល់ពីក្រោយសម្រាប់ទប់លំនឹងពេលបញ្ឈរក្តារពាស តាមគំនិតច្នៃប្រឌិតរៀងៗខ្លួន។





**ខ. ក្តារខៀន៖** ករណីគ្មានក្តារពាសដូចខាងលើ គ្រូអាចប្រើក្តារខៀនសរសេរធម្មតាបាន ដោយគ្រាន់តែយកកំណាត់សំឡីមួយផ្ទាំងមកបិទពីលើក្តារខៀន។

**គ. ផលិតតួអង្គក្នុងសាច់រឿង៖**




- គូរ ឬថតចម្លងរូបភាពតួអង្គ ឬឈុតឆាកនៃរឿងដែលចង់បានពីសៀវភៅ ដាក់លើកំណាត់ក្រដាសកាតុង
- ផាត់ពណ៌តាមការច្នៃប្រឌិតរៀងៗខ្លួន
- កាត់តាមរាងតួអង្គនីមួយៗ រួចយកក្រដាស ឬដែកដុសខ្នាំងមកកោសឱ្យបែកព្រុយ ដើម្បីងាយបិទជាប់លើក្តារពាស។

### ២. របៀបនិទានរឿង



- ផ្ទៀងផ្ទាត់ថាតួអង្គបានរៀបចំតាមលំដាប់លំដោយ
- រៀបចំកន្លែងសម្រាប់ដាក់តួអង្គនៅក្បែរក្តារខៀន ឬក្តារពាស
- រៀបចំផ្ទាំងកំណាត់សំឡី ឬក្តារពាសឱ្យមានលំនឹងល្អ
- ពេលនិទានលើកបង្ហាញតួអង្គដល់អ្នកមើល និងស្តាប់ដោយកាន់ឲ្យចំរូបកុំឱ្យបាំងដៃរួចយកទៅបិទឱ្យត្រូវចំកន្លែង និយាយរៀបរាប់តាមដំណើររឿង( ដាក់តួអង្គថ្មីទើបដកតួអង្គមុន )
- មុនពេលបិទរូបតួអង្គលើក្តារពាស អ្នកនិទានត្រូវធ្វើចលនារូបភាពតាមសាច់រឿង និងលើកដាក់សំឡេងតាមចលនាតួអង្គលោត រត់ សើច យំ ស្រែក ជាដើម។

Scanned with MOBILE SCANNER

## ៤. និទានរឿងដោយតុក្កតា ឬអាយ៉ង (តុក្កតា ស្រោមដៃ រូបដោត អាចរៀម)

### ☛ និទានរឿងដោយតុក្កតា



ការជ្រើសរើសយកតុក្កតាមកបម្រើឱ្យការនិទានរឿង ដោយសារកុមារនិយមចូលចិត្តលេងតុក្កតា ដូច្នេះហើយការនិទានរឿងដោយប្រើតុក្កតាធ្វើឱ្យមានប្រសិទ្ធភាពក្នុងការសិក្សារបស់កុមារ។ រឿងដែលជ្រើសរើសយកមកនិទាន ត្រូវឱ្យសមស្របទៅតាមវ័យរបស់កុមារមិនត្រូវមានឈុតឆាក និងតួអង្គច្រើនពេកនោះទេ។

### ១. សម្ភារឧបទេស

និទានរឿងដោយប្រើតុក្កតា គឺជាការនិទានរឿងដោយយកតុក្កតាជាតំណាងឱ្យតួអង្គទាំងឡាយនៅក្នុងរឿងនិទាន ដូចជា មនុស្ស សត្វ បន្លែ ផ្លែឈើជាដើម។ គ្រូអាចផលិតតុក្កតាដោយខ្លួនឯង ឬក៏អាចទិញនៅតាមទីផ្សារបានឱ្យតែសមស្របទៅតាមសាច់រឿងដែលត្រូវយកមកនិទាន។

**របៀបផលិត**



១. កាត់ក្រដាសកាតុង ២. គូរ ផ្គាម ឬព្រីនរូបតួអង្គ រួចកាត់រូបចេញពីផ្ទាំងក្រដាស ៣. ផាត់ពណ៌រូបតួអង្គ



### ២. របៀបនិទានរឿង

- ពិនិត្យ និងរៀបចំតុក្កតាផ្គាប់តាមលំដាប់លំដោយនៃសាច់រឿង
- ពេលនិទានត្រូវលើកតួអង្គតុក្កតាបង្ហាញតាមឆាកឈុតនៃសាច់រឿង បញ្ចេញតួអង្គម្តងមួយៗ កាន់បង្ហាញកុំឱ្យបាំងដៃ ប្រែប្រួលទឹកមុខ លើកដាក់សំឡេង រក្សាសំឡេង របស់តួអង្គនីមួយៗ។ ក្នុងករណីតួអង្គពីរជជែកគ្នា ត្រូវប្រើដៃទាំងពីរកាន់តុក្កតាម្ខាងមួយ និងធ្វើកាយវិការតាមសកម្មភាពតួអង្គ។ តួអង្គណាដែលបង្ហាញរួចហើយ អាចផ្កាប់រូបចុះក្រោម។
- ពោល និងពណ៌នាតាមដំណើររឿងដោយប្រើសំឡេងធម្មជាតិ។









PDF Scanned with MOBILE SCANNER

## គន្លឹះបន្ថែម

ក្នុងការផលិតតុក្កតា យើងអាចជ្រើសរើសសម្ភារផលិតបានច្រើនដូចជាក្រដាសកាតុង ប្រអប់ក្រដាស ដីឥដ្ឋ ស្រោមជើង បន្លែផ្លែឈើស្រស់ជាដើម។ ខាងក្រោមនេះជាឧទាហរណ៍៖

### ១. ផលិតតុក្កតាពីកំណាត់




គូររូបព្រាងធ្វើពុម្ព




កាត់កំណាត់តាមពុម្ព មានពីរស្រទាប់ គឺស្រទាប់លើ និងស្រទាប់ក្រោម




ដេរស្រទាប់ទាំងពីបញ្ចូលគ្នា និងញាត់សំឡីគចូលខាងក្នុង

### ២. ផលិតតុក្កតាពីដីឥដ្ឋ










១. ជ្រើសរើសដីឥដ្ឋធម្មជាតិ ឬដីឥដ្ឋទីផ្សារ ២. សូនរូបតួអង្គ
៣. តុបតែងតួអង្គដោយផាត់ពណ៌ ឬបន្ថែមគ្រឿងលម្អផ្សេងៗ

### ៣. ផលិតតុក្កតាពីស្រោមជើង

យើងអាចយកស្រោមជើងមកផលិតជាតួអង្គបានច្រើនប្រភេទ។ ខាងក្រោមគឺជាការផលិតជារូបដង្កូវ។










១. ជ្រើសរើសស្រោមជើងប្រើរួច ដែលបានបោកសម្អាត
២. ញាត់សំឡី គតាមថ្នាក់នីមួយនៃរូបដង្កូវ រួចយកអំបោះរឹតចងជាកង់ៗ ដោយផ្នែកខាងក្រោយរឹតឱ្យស្អួចធ្វើជាកន្ទុយ។
៣. តុបតែង និងផាត់ពណ៌៖ យកឡេវអាវធ្វើជាភ្នែក លួសធ្វើជាប្រមោយ កំណាត់ក្រហមធ្វើមាត់។

### ៤. ផលិតតុក្កតាពីបន្លែ ផ្លែឈើ និងសម្បកកំប៉ុង

យើងអាចផលិតតួអង្គពីបន្លែ ផ្លែឈើ និងសម្បកកំប៉ុងមួយចំនួន ដោយធានាសុវត្ថិភាព និងអនាម័យដល់កុមារ។ ឧទាហរណ៍៖










១. ជ្រើសរើសបន្លែ ផ្លែឈើ
២. គូរព្រាងរូបតួអង្គ
៣. កាត់ ចិត ចោះ
៤. តុបតែងដោយផាត់ពណ៌




Scanned with MOBILE SCANNER

## ➛ និទានរឿងដោយស្រោមដៃ



ការនិទានរឿងដោយប្រើស្រោមដៃ គឺជាការយកស្រោមដៃមកពាក់សម្រាប់និទានរឿង ដែលស្រោមដៃនោះប្រៀបបីដូចជាឆាកសម្តែង ឬជាផ្ទាំងទស្សនីយភាពនៃរឿងមួយ។ អ្នកនិទានបញ្ចេញតួអង្គម្តងមួយៗ ព្រមទាំងធ្វើសកម្មភាពសម្តែងតាមព្រឹត្តិការណ៍នៃសាច់រឿង។ រឿងដែលជ្រើសរើសមកនិទាន ត្រូវឱ្យសមស្របទៅតាមវ័យរបស់កុមារ និងមិនគួរមានឈុតឆាកច្រើនពេកទេ។

### ១. សម្ភារឧបទេស

ការផលិតស្រោមដៃសម្រាប់និទានរឿងមានភាពខុសគ្នាតាមសាច់រឿង និងការច្នៃប្រឌិតរបស់អ្នកផលិត។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះ៖

**ក. សម្ភារសម្រាប់ផលិត**



ស្រោមដៃប្រើរួច



កំទេចកំណាត់ចម្រុះពណ៌



សំឡីគ



អំបោះ និងម្ជុលដេរ



**ខ. របៀបផលិត**




របៀបទី១៖ ១. ជ្រើសរើសស្រោមដៃប្រើរួចបោកស្អាត ២. ចងគួចស្រោមដៃផ្នែកខាងចុងម្រាមធ្វើក្បាល ៣.តុបតែងធ្វើមុខមាត់តួអង្គ និងឆាក




របៀបទី២៖ ១. ជ្រើសរើសស្រោមដៃប្រើរួចបោកស្អាត ២. ដេរស្អុតញីឈ្មោលនៅផ្នែកខាងចុងម្រាមទុកបិទតួអង្គ និងនៅបាតដៃសម្រាប់បិទឆាក ៣. បិទតួអង្គលើម្រាមដៃ និងឆាក។

*បញ្ជាក់៖ ការផលិតបែបនេះអាចឱ្យយើងប្រើស្រោមដៃបានច្រើនរឿង ដោយគ្រាន់តែផលិតតួអង្គ និងឆាកមកបិទពីលើ។*

### ២. របៀបនិទានរឿង

- រឿងដែលជ្រើសរើសយកមកនិទាន ជាទូទៅមានតួអង្គចំនួន៣ ទៅ៥តែប៉ុណ្ណោះ បើលើសពីនេះ អ្នកនិទានត្រូវប្រើស្រោមដៃពីរ ពាក់ដៃទាំងពីរ។
- ពាក់ស្រោមដៃដែលបានផលិតរួចហើយ ឱ្យបានត្រឹមត្រូវស៊ិបស្និទ្ធល្អ។
- ពេលនិទាន ត្រូវលើកបង្ហាញស្រោមដៃ មានតួអង្គតុក្កតា តាមឈុតឆាកនៃសាច់រឿង បង្ហាញតួអង្គម្តងមួយៗ កុំឱ្យបាំងដៃ ប្រែប្រួលទឹកមុខ លើកដាក់សំឡេង រក្សាសំឡេង របស់តួអង្គនីមួយៗ។ ក្នុងករណីតួអង្គពីរជជែកគ្នា ត្រូវប្រើម្រាមដៃពីរ និងធ្វើកាយវិការតាមសកម្មភាពតួអង្គ។
- ចំពោះស្រោមដៃដែលបិទតុក្កតា ត្រូវនិទានបណ្តើរបិទតួអង្គតុក្កតានៅលើម្រាមដៃបណ្តើររហូតដល់ចប់។

Scanned with MOBILE SCANNER

## ➤ និទានរឿងដោយរូបដោត



ការនិទានរឿងដោយរូបដោតមានលក្ខណៈស្រដៀងគ្នានឹងការនិទានរឿងដោយរូបបិទដែរ គ្រាន់តែយកតួអង្គដែលផលិតមកដាក់ដងដោតលើឆាកផលិតពីបន្ទះស្នោរ កំណាត់ដើមចេក ឬដីខ្សាច់។ ការនិទានរឿងប្រភេទនេះទាក់ទាញកុមារកាន់តែខ្លាំងប្រសិនបើអ្នកនិទានចេះច្នៃប្រឌិតឆាកឱ្យមានភាពស្រស់ស្អាត។ រឿងដែលជ្រើសរើសយកមកមិនគួរមានឈុតឆាក និងតួអង្គច្រើនពេកទេ។

### ១. សម្ភារឧបទេស

ការផលិតសម្ភារឧបទេសមានភាពខុសគ្នាតាមសាច់រឿង និងការច្នៃប្រឌិតរបស់អ្នកផលិត។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះ៖

#### ក. ការផលិតឆាក

ឆាកអាចផលិតពីសម្ភារសាមញ្ញៗច្រើនប្រភេទ ដូចជាកំប៉ុងដីខ្សាច់ ចានដែកដីខ្សាច់ ស្នោរ អេប៉ុងជាដើម។ ឆាកត្រូវមានលំនឹងល្អ និងងាយស្រួលដោតរូប រីឯការតុបតែងគឺអាស្រ័យលើការច្នៃប្រឌិតរបស់អ្នកផលិត។



កំប៉ុងដីខ្សាច់



ចានដែកដីខ្សាច់



បន្ទះស្នោរ



បន្ទះអេប៉ុង



#### ខ. ការផលិតតួអង្គ

ការផលិតតួអង្គគឺស្រដៀងគ្នានឹងការនិទានរឿងដោយតុក្កតាដែរ ដោយយើងគ្រាន់តែថែមដងដោតលើតុក្កតា សម្រាប់ដោតបញ្ឈរលើឆាក។ ភាគច្រើន ការផលិតតួអង្គមានមុខពីរព្រោះងាយស្រួលបង្វិលទិសដៅតួអង្គក្នុងឈុតឆាកសន្ទនា។ ខាងក្រោមនេះជារបៀបផលិត។










១. ផលិតតួអង្គពីរដូចគ្នា តែជារូបបញ្ច្រាសគ្នា

២. បិទការលើរូបទាំងពីរ រួចយកដងឬស្សីបិតស្អាត មានប្រវែងប្រមាណ២០ទៅ៣០សង់ទីម៉ែត្រ ដាក់ចំកណ្ដាល

៣. បិទរូបទាំងពីរបញ្ចូលឱ្យត្រួតស៊ីគ្នា។

### ២. របៀបនិទានរឿង

- រៀបចំឆាកឱ្យបានត្រឹមត្រូវ ហើយត្រូវផ្ទៀងផ្ទាត់ថាអ្នកបានរៀបចំតួអង្គតាមលំដាប់លំដោយ
- និទានបណ្ដើរ លើកតួអង្គបង្ហាញបណ្ដើរ រួចយកទៅដោតលើឆាក
- ករណីត្រូវបង្ហាញតួអង្គពីរដេដែកគ្នា យើងត្រូវប្រើដៃទាំងពីរកាន់រូបម្ខាងមួយ ធ្វើកាយវិការតាមដំណើររឿង
- ពេលតួអង្គនិយាយគ្នា ចៀសវាងដាក់តួអង្គបែរខ្នងដាក់គ្នា។

Scanned with MOBILE SCANNER

## គន្លឹះបន្ថែម

ការផលិតសម្ភារសម្រាប់រឿង ផ្លែប៉ែនធំលេងពួន



### ១. ការផលិតសម្ភារ



- នៅក្នុងរឿងនេះមានតួអង្គសំខាន់ពីរគឺ នារី និងផ្លែប៉ែន។ អ្នកនិទានថតចម្លងពណ៌ពីសៀវភៅរឿង រួចកាត់ និងបិទជងដោត។
- ឆាកផលិតពីបន្ទះស្នោរចាស់ៗ ដោយអ្នកនិទានច្នៃធ្វើផ្ទះមានរបង តុបតែងដាក់ផ្កា ស្មៅ និងស្លឹកឈើជាដើម ដោយយកលំនាំពីក្នុងសៀវភៅ។



- តួអង្គ«នារី»បានថតចម្លងជាច្រើនតាមចលនាក្នុងសាច់រឿង ដូចជាដើរ លោត រត់ ឡើងជណ្ដើរ...។



- ដើម្បីងាយស្រួលចាំលំដាប់តួអង្គតាមសកម្មភាពក្នុងសាច់រឿង អ្នកនិទានបានបង់លេខនៅខាងក្រោយ តាមលំដាប់លំដោយ។ ការធ្វើបែបនេះងាយស្រួលដល់ការនិទានពេលក្រោយៗទៀតផងដែរ។

បញ្ជាក់៖

- កម្មសិទ្ធិបញ្ញា៖ ច្បាប់កម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជាបានចែងថារាល់ការប្រើប្រាស់ ការផលិតឡើងវិញ ឬធ្វើអាជីកម្មលើស្នាដៃរបស់អ្នកដទៃត្រូវមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញា។ អង្គការសន្តិស្ម័គ្រចិត្ត(SVA)មានកម្មសិទ្ធិបញ្ញាស្របច្បាប់លើស្នាដៃរឿង ផ្លែប៉ែនលេងពួន ហើយស្ថាប័ននេះមិនបានរឹតបណ្ដឹងទៅលើការផលិតឡើងវិញនូវស្នាដៃ ក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណូល និងអប់រំនោះទេ។

Scanned with MOBILE SCANNER

## ➤ និទានរឿងដោយអាវអៀម



និទានរឿងដោយប្រើអាវអៀម គឺជាការយកអាវអៀមមកពាក់សម្រាប់និទានរឿង ដែលអាវអៀមនោះប្រៀបបីដូចជាឆាកសម្តែងរឿង ហើយអ្នកនិទានរក្សាទុកតួអង្គនៅក្នុងហោប៉ៅ។ អ្នកនិទានធ្វើចលនា ឬបិទតួអង្គនៅលើអាវអៀមទៅតាមដំណើររឿង។ រឿងដែលជ្រើសរើសមកនិទាន ត្រូវឱ្យសមស្របទៅតាមវ័យរបស់កុមារ និងមិនគួរមានឈុតឆាកច្រើនពេកទេ។

អាវអៀមបង្កើតឡើងដោយផ្ទាំងកំណាត់ ដេរប៉ាក់ភ្ជាប់បកបិទ(ស្កុតញីឈ្មោល)សម្រាប់បិទតុក្កតា។ អាវអៀមពាក់ពីខាងមុខ មានខ្សែបួនសម្រាប់ចងទៅខាងក្រោយខ្នងអ្នកនិទានរឿង។ អាវអៀមមួយដេរប៉ាក់បានច្រើនរឿងនិទានដោយដេរហោប៉ៅអាវអៀម។

### ១. សម្ភារឧបទេស

#### ក. សម្ភារសម្រាប់ផលិត



កំណាត់ចាស់ៗ (ក្រួយស្តើងៗ)



កំទេចកំណាត់ចាស់ៗ ចម្រុះពណ៌



ស្កុត (ស្កុតញី ឈ្មោល)



អំបោះ ម្ជុល ឬបើមានម៉ាស៊ីនដេរកាន់តែប្រសើរ



#### ខ. របៀបផលិត

១




កាត់ដេរកំណាត់រាងអាវអៀម មានទំហំល្មមនឹងដងខ្លួនរបស់អ្នកនិទាន។

កាត់ដេរខ្សែចងចំនួន៤

២




កាត់ដេរហោប៉ៅតាមរូបរាង និងទំហំដែលចង់បាន។

៣



យកកំណាត់ពណ៌កាត់ដេរជារូបរាងផ្សេងៗ សម្រាប់បិទតុបតែងធ្វើជាឆាក។



ដេរភ្ជាប់ស្កុតញី ឬឈ្មោលទៅនឹងឆាកអាវអៀមសម្រាប់បិទតួអង្គតុក្កតា។

៤



ការផលិតតួអង្គតុក្កតាដូចគ្នានឹងការនិទានរឿងដោយតុក្កតាខាងលើដែរ តែដេរភ្ជាប់ស្កុតញីឈ្មោលសម្រាប់បិទលើអាវអៀម។

### ២. របៀបនិទានរឿង

- ពាក់អាវអៀម ហើយផ្ទៀងផ្ទាត់ឱ្យច្បាស់ថាតួអង្គត្រូវបានរៀបចំ និងចំណាំលំដាប់លំដោយតួអង្គមុនពេលនិទានរឿង
- ពេលនិទានត្រូវលើកតួអង្គតុក្កតាបង្ហាញតាមឆាកឈុតនៃសាច់រឿង បញ្ចេញតួអង្គម្តងមួយៗ កាន់បង្ហាញកុំឱ្យបាំងដៃ ប្រែប្រួលទឹកមុខ លើកដាក់សំឡេង រក្សាសំឡេង របស់តួអង្គនីមួយៗ
- ក្នុងករណីតួអង្គពីរជជែកគ្នា ត្រូវប្រើដៃទាំងពីរកាន់តុក្កតាម្ខាងមួយ និងធ្វើកាយវិការតាមសកម្មភាពតួអង្គ។ បន្ទាប់មកបិទតួអង្គនៅលើឆាកអាវអៀម ហើយ ចាប់ប្រឹចយកតួអង្គបន្តបន្ទាប់ទៀត។




ដាក់តួអង្គចេញក្រោយចូលក្នុងហោប៉ៅមុន ដូច្នេះតួអង្គដែលត្រូវចេញមុនងាយទាញចេញ

Scanned with MOBILE SCANNER

## ៥. និទានបណ្ដើរ គូររូបបណ្ដើរ



ការនិទានបណ្ដើរគូររូបបណ្ដើរ ជាការគូររូបនៅលើក្ដារខៀន ឬផ្ទាំងក្រដាសធំមួយតាមដំណើរសាច់រឿងដែលបាននិទាន។ ការនិទានប្រភេទនេះមានភាពងាយស្រួល និងទាក់ទាញដោយសាររូបភាពដែលគូរចេញបន្តិចម្ដងៗគឺជាសកម្មភាពមួយដែលទាក់ទាញដល់កុមារឱ្យចូលចិត្តមើល និងស្ដាប់ការនិទានជាមួយគ្រូពីដើមរហូតដល់ចប់។ បន្ទាប់ពីនិទានចប់ រូបភាពតំណាងឱ្យសាច់រឿងទាំងមូលក៏ត្រូវបានគូរចប់សព្វគ្រប់ដែរ។ រឿងដែលជ្រើសរើសយកមកមិនគួរមានឈុតឆាក និងតួអង្គច្រើនពេកទេ។

### ១. សម្ភារឧបទេស

- ដី ស ឬហ្វឺតមានពណ៌ផ្សេងៗគ្នា
- ក្ដារខៀន ឬក្រដាសផ្ទាំងធំ
- កំណាត់សម្រាប់លុប និងសម្ភារជំនួយផ្សេងៗប្រសិនបើមាន។

### ២. របៀបនិទានរឿង

- ហ្វឹកហាត់គូររូបលើក្ដារខៀនជាមុនដើម្បីឱ្យស៊ាំនឹងលំហូរនៃការគូររូបតាមសាច់រឿង
- រៀបចំក្ដារខៀន ឬផ្ទាំងក្រដាសធំ និងហ្វឺត ឬដី សទុកជាមុន
- ក្នុងករណីមានតួអង្គពីរនិយាយឆ្លើយឆ្លងគ្នា គូររូបភាពតួអង្គទាំងនោះនៅជិតគ្នា
- អ្នកនិទានគួរជៀសវាងគូរលុបៗច្រើនដង នាំឱ្យអូសបន្លាយពេលវេលានៃការនិទានរឿង។



និទានបណ្ដើរ គូររូបបណ្ដើរ រឿង ក្អែកវៃឆ្លាត



រូបគំនូរពេលរឿងបានបញ្ចប់នៅលើក្ដារខៀន

Scanned with MOBILE SCANNER

## ៦. សម្តែងតួតាមសាច់រឿង (កុមារដើរតួផ្ទាល់)



និទានរឿងដោយសម្តែងតួ គឺជាការធ្វើសកម្មភាពរបស់កុមារតាមសាច់រឿងដែលពួកគាត់ធ្លាប់បានស្តាប់រឿងនិទានចប់។ កុមារមានចំណាប់អារម្មណ៍ថាពួកគាត់ជាតួអង្គពិតៗនៅក្នុងសាច់រឿង។ ដូច្នេះគ្រូលើកទឹកចិត្តឱ្យកុមារសម្តែងដើរតួផ្ទាល់តាមសាច់រឿង ដែលគ្រូបាននិទានរឿងចប់។ ការសម្តែងតួមានប្រសិទ្ធភាពសម្រាប់កុមារពីព្រោះពួកគេអាចរៀនពីការចូលរួមជាមួយអ្នកដទៃ ចេះស្រមើស្រមៃ ចេះគិត យល់រឿងនិទាន ដឹងអត្ថន័យភាសា មានសមត្ថភាពប្រើភាសា និងចំនួនពាក្យកើនឡើងយ៉ាងលឿនបំផុត។ កុមារចេះធ្វើការងារជាក្រុម និងធ្វើឱ្យពួកគាត់មានទំនុកចិត្តហើយបង្កើនសមត្ថភាពក្នុងការសម្តែងរឿង។ រឿងនិទានដែលជ្រើសរើសយកមកមិនគួរមានឆាកឈុត និងតួអង្គច្រើនពេកទេ។

### ១. សម្ភារឧបទេស

- និទានរឿងដោយសម្តែងតួ គឺកុមារដើរតួផ្ទាល់ជំនួសតួអង្គជាមនុស្ស សត្វ វត្ថុ បន្លែ ឬផ្លែឈើជាដើម។ គ្រូអាចផលិតជាមួយកុមារ ឬទិញនៅទីផ្សារ។ កុមារស្ម័គ្រចិត្តដើរតួតាមចំណូលចិត្តដោយសេរីភាព។

### ២. របៀបផលិត

- គូររូបមុខ ឬក្បាលតួអង្គក្នុងសាច់រឿង ផាត់ពណ៌ កាត់បិទធ្វើបូពាក់ក្បាលអ្នកដើរតួ។

### ៣. របៀបសម្តែងតួ

- គ្រូសម្របសម្រួលកុមារឱ្យដើរតួ និងតុបតែងខ្លួនពាក់បូមានរូបតួអង្គ
- ពេលនិទានរឿងដោយសម្តែងតួ តួអង្គត្រូវចេញតាមឆាកឈុតនៃសាច់រឿង តួអង្គនីមួយៗបញ្ចេញសំដី បន្លឺសំឡេង ធ្វើកាយវិការសម្តែងតាមតួតាំងពីដើមរហូតដល់ចប់ ក្រោមការជ្រោមជ្រែងរបស់គ្រូ។



គ្រូនិទានរឿងមុនពេលឱ្យកុមារសម្តែងរឿង



គ្រូបង្ហាញតួអង្គនីមួយៗឱ្យកុមារបានដឹង

Scanned with MOBILE SCANNER



# ជំពូកទី៤

## ការអភិវឌ្ឍរឿងនិទានទៅជា សកម្មភាពផ្សេងៗ

Scanned with MOBILE SCANNER

ការយករឿងនិទានទៅផ្សារភ្ជាប់នឹងសកម្មភាពផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់កុមារ ដែលពួកគេជាទូទៅតែងតែចូលចិត្តជាមួយសកម្មភាពដទៃទៀត។ សូមអនុវត្តន៍រឿងនិទានឱ្យបានបម្រើដល់មុខវិជ្ជាទាំងប្រាំ(ចិត្តចលភាព បុរេគណិត ភាសាខ្មែរ វិទ្យាសាស្ត្រ និងសិក្សាសង្គម) តាមដែលអាចធ្វើទៅបាន និងសកម្មភាពសមស្របនានា តាមរយៈការនិទានរឿង ឬសៀវភៅរូបភាព ដូចជាទស្សនាសង្កេត(សត្វ រុក្ខជាតិ ឬវត្ថុផ្សេងៗ) គូររូបភាពផ្សេងៗ និងការសម្តែងតួជាដើម។ ការធ្វើបែបនេះនឹងនាំឱ្យកុមារមានការអភិវឌ្ឍវិស័យទាំង៥កាន់តែទូលំទូលាយ ប្រសើរឡើងថែមទៀត។

ការប្រើប្រាស់រឿងនិទាន ឬសៀវភៅរូបភាពសម្រាប់សកម្មភាពថ្នាក់រៀនមានសារៈសំខាន់ចំពោះការបង្រៀន និងរៀនតាមរយៈការលេង និងបរិស្ថានឱ្យមានភាពរស់រវើក និងសប្បាយរីករាយ។

## រឿងនិទាន ឬសៀវភៅរូបភាពប្រើប្រាស់ក្នុងការបង្រៀន និងរៀនប្រចាំថ្ងៃ






## បញ្ជីឈ្មោះសកម្មភាពបន្ទាប់ពីនិទានរឿងចប់

| ល.រ | ឈ្មោះសកម្មភាព | ពណ៌នា |
|---|---|---|
| ១ | អំណានសេរី  | ក្រោយពីបានស្តាប់រឿងនិទានចប់ កុមារនឹងមានចំណាប់អារម្មណ៍ ចង់ចេះ ចង់យល់ដឹងបន្ថែមទៀត។ ទោះបីកុមារមិនចេះអាន ប៉ុន្តែពួកគាត់អាចអានរូបភាពទៅជាសាច់រឿងមួយបានតាមពាក្យពេចន៍ដែលគាត់ពណ៌នារូបភាពទាំងនោះដោយខ្លួនឯង។ ដើម្បីបំពេញតម្រូវការ ចង់យល់ ចង់ដឹងរបស់កុមារ គ្រូគួរតែរៀបចំបរិស្ថានសម្រាប់អានដូចជាជ្រុងសិក្សា ហើយណែនាំពីសៀវភៅល្អៗគឺរឹតតែប្រសើរ។<br>ដូច្នេះគ្រូត្រូវផ្តល់ពេលវេលាឱ្យកុមារស្វែងរកសៀវភៅរឿងនិទាននោះ ឬសៀវភៅផ្សេងៗទៀតនៅធ្នើរសៀវភៅ ឬបណ្ណាល័យសម្រាប់អាន។ |
| ២ | គូររូបភាពតាមចំណូលចិត្តក្នុងសាច់រឿងនិទាន  | បន្ទាប់ពីនិទានរឿងចប់ គ្រូឃើញប្រតិកម្មកុមារចង់គូររូប។ ដូច្នេះ គ្រូរៀបចំសកម្មភាពគំនូរសេរីពីសាច់រឿងតាមការស្រមើស្រមៃរបស់កុមារ។ គ្រូបែងចែកកុមារជាក្រុមតូចៗ និងផ្តល់សម្ភារគំនូរ ហើយពួកគេចាប់ផ្តើមគូរនូវអ្វីដែលខ្លួនចូលចិត្ត។ បន្ទាប់មក គ្រូប្រមូលស្នាដៃទាំងនោះដាក់តាំងនៅជ្រុងសិល្បៈ។<br>សកម្មភាពគំនូរបែបនេះធ្វើឱ្យកុមារកាន់តែរីករាយជាមួយនឹងរឿងនិទាន ដោយគេបានបង្ហាញនូវចំណាប់អារម្មណ៍ពីការស្រមើស្រមៃតាមរយៈគំនូរ។ |
| ៣ | ការសង្កេត  | គ្រូអាចភ្ជាប់ការនិទានរឿងជាមួយការសង្កេត ឬសកម្មភាពវិទ្យាសាស្ត្រ។ ឧទាហរណ៍៖ បន្ទាប់ពីគ្រូនិទានរឿងអំពីផ្កា «កុលាបពីរទង» គ្រូគួរតែនាំកុមារចេញទៅខាងក្រៅថ្នាក់ដើម្បីមើលផ្កាពិតប្រាកដ។ គ្រូអាចរៀបចំជ្រុងវិទ្យាសាស្ត្រជាមួយធម្មជាតិ និងសៀវភៅរូបភាព ដែលគ្រូបាននិទានដើម្បីឱ្យកុមារសង្កេតនៅពេលសម្រាក។<br>កុមារចូលចិត្តប្រៀបធៀបធម្មជាតិពិតនឹងសៀវភៅវិទ្យាសាស្ត្រ។ កុមាររីករាយជាមួយរូបភាព ឬគំនូរ។ |

Scanned with MOBILE SCANNER

| | | |
|---|---|---|
| ៤ | សកម្មភាពបណ្ណាល័យ  | បើទោះបីជារឿងនិទានបានបញ្ចប់ ភាគច្រើនកុមារកំពុងតែស្ថិតនៅក្នុងពិភពរឿងនិទាននោះនៅឡើយ ដូច្នេះ គ្រូគួរផ្តល់ឱកាសឱ្យកុមារទៅស្វែងរកសៀវភៅ ឬរឿងដែលគាត់ចាប់អារម្មណ៍ នៅជ្រុងសិក្សា ឬបន្ទប់បណ្ណាល័យសាលារៀន (បើមាន)។<br>ការប្រើប្រាស់បណ្ណាល័យពិតជាមានសារៈសំខាន់ណាស់ ពីព្រោះមានសៀវភៅច្រើនប្រភេទ និងល្បែងសិក្សាផ្សេងៗទៀតដែលជំនួយដល់ការអភិវឌ្ឍបញ្ញារបស់កុមារ។ គ្រូអាចនិទានរឿងនៅបណ្ណាល័យ ឬឱ្យបណ្ណារក្សជាអ្នកនិទាន។ កុមារនឹងមានភាពស៊ាំទៅនឹងបណ្ណាល័យ ហើយកុមារគិតថាបណ្ណាល័យជាកន្លែងគួរជាទីរីករាយ និងអាចក្លាយជាអ្នកពូកែអាននៅថ្ងៃអនាគត។ |
| ៥ | សកម្មភាពកសាង៖ កាត់ ឬហែកបិទរូបតាមការស្រមើស្រមៃពីសាច់រឿង  កាត់បិទរូបក្អែក និងក្អមទឹក | ក្រោយពីនិទានរឿងចប់ គ្រូសម្របសម្រួលដល់ក្រុមកុមារផ្តល់សម្ភារ ក្រដាសពណ៌ ខ្មៅដៃពណ៌ កាវ ហ្វឺត កន្ត្រៃ...។ គ្រូណែនាំកុមារឱ្យយកចំរៀកក្រដាសពណ៌មកផ្គុំលើក្រដាសរាមបង្វិលមើលប្រដូចទៅរូបភាពសត្វ ភ្នំ រុក្ខជាតិ ដើម្បីបង្កើតជារូបភាពផ្សេងៗ និងតុបតែងបន្ថែម រួចដាក់ឈ្មោះរូបភាពនោះ តាមការស្រមើស្រមៃរបស់កុមារ។ |
| ៦ | ល្បែងក្រៅថ្នាក់៖ ល្បែងត្រាប់តាមអ្នកលក់ដូរ(លក់បន្លែនៅអាងខ្សាច់)  | បន្ទាប់ពីនិទានរឿងចប់ គ្រូចែកកុមារជាពីរក្រុម មានក្រុមអ្នកលក់ និងអ្នកទិញ ហើយនាំកុមារទៅលេងល្បែងលក់ដូរបន្លែនៅអាងខ្សាច់ ដោយគ្រូចែកសម្ភារ ដូចជា ក្រដាស ឬស្លឹកឈើធ្វើជាក្រដាសប្រាក់ឱ្យអ្នកទិញ និងសម្ភារមួយចំនួនទៀតឱ្យក្រុមលក់ដូចជា ពុម្ពបន្លែ សម្រាប់យកដីខ្សាច់សើមមកចាក់ពុម្ពជាបន្លែលក់។ ក្រុមលក់ចាក់ពុម្ពបានបន្លែតម្រៀបលើរានលក់បន្លែ ក្រុមអ្នកទិញដើរជ្រើសរើសបន្លែតថ្លៃទិញយ៉ាងសប្បាយរីករាយ។ |




ការផលិតសំបុកដង្កូវ៖ គ្រូបាននិទានរឿង "ដង្កូវពណ៌ខៀវ" ឱ្យកុមារស្តាប់។ នៅម៉ោងបន្ទាប់គ្រូបាននាំកុមារសង្កេត និងសន្ទនាពីវដ្តនៃការអភិវឌ្ឍរបស់សត្វដង្កូវ។ ក្រោមមក កុមារផលិតសំបុកដង្កូវពីស្នូលក្រដាសជូតមាត់ ឬដបទឹក តាមការស្រមើស្រមៃពីសាច់រឿង និងការសង្កេតខាងលើ។

Scanned with MOBILE SCANNER

## ឧទាហរណ៍

### ការនិទានរឿងផ្ទាល់មាត់ដោយកុមារបន្ទាប់ពីនិទានរឿង

ប្រសិនបើកុមារចាប់អារម្មណ៍ចង់និទានរឿង គ្រូគួរតែលើកទឹកចិត្តឱ្យពួកគេបាននិទាន។ កុមារនឹងមានទំនុកចិត្តលើខ្លួនឯងក្រោយពេលបាននិទានរឿងនៅចំពោះមុខអ្នកដទៃ ធ្វើឱ្យកុមារផ្សេងៗទៀតក៏មានទឹកចិត្តចង់សាកល្បងនិទានរឿងដែរ។ ខាងក្រោមនេះជាឧទាហរណ៍អំពីការនិទានរឿងរបស់កុមារបន្ទាប់ពីស្ដាប់រឿង កូនពពែវៃឆ្លាត។

| | |
|---|---|
| មុខវិជ្ជា | - ភាសាខ្មែរ៖ រឿងនិទាន |
| សកម្មភាព | - រឿងនិទាន |
| ចំណងជើងមេរៀន | - កូនពពែវៃឆ្លាត |
| ថ្នាក់/អាយុ | - កម្រិតខ្ពស់(៥ឆ្នាំ) |
| រយៈពេល | - ៣០នាទី(១ម៉ោងសិក្សា) |
| សម្ភារ | - សៀវភៅនិទានរឿង«កូនពពែវៃឆ្លាត» រៀបចំនៅជ្រុងសិក្សា(ធ្នើរដាក់សៀវភៅ)<br>- កម្រាលអេប៉ុង ឬកន្ទេលសម្រាប់កុមារអង្គុយស្ដាប់រឿងនិទាន |
| របៀបដំណើរការ | - និទានរឿងដោយកុមារ |

### ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

**បរិស្ថាន**



- រៀបចំតុទៅម្ខាង ឱ្យកុមារអង្គុយលើកៅអីជារាងអក្សរ អ៊ុយ(U)។
- រៀបចំកៅអីមួយសម្រាប់គ្រូអង្គុយនិទានរឿង។

**ការចូលរួមរបស់គ្រូ**



- នៅពេលនិទានរឿងចប់ គ្រូដឹងថាកុមារចង់និទានរឿងតាមអ្នកគ្រូ ដើម្បីទាញការចាប់អារម្មណ៍របស់កុមារនៅចុងបញ្ចប់នៃសាច់រឿង គ្រូបានបំផុសដល់កុមារស្ម័គ្រចិត្តឡើងនិទានឡើងវិញ។
- បានចូលរួមជាមួយសិស្ស និងជ្រោមជ្រែងឱ្យកុមារនិទានរឿងរហូតដល់ចប់។



### ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល







គ្រូបាននិទានរឿង កូនពពែវៃឆ្លាត ឱ្យកុមារស្ដាប់។ គ្រូបានសួរទៅកុមារ «តើកូនៗណាចង់សាកល្បងនិទានរឿងដែលគ្រូទើបបាននិទានឱ្យមិត្តភក្ដិយើងបានស្ដាប់ដែរ ឬទេ?»។ កុមារជាច្រើនបានលើកដៃ ហើយឆ្លើយថា «ខ្ញុំៗ...»។ គ្រូដឹងថាក្នុងចំណោមកុមារដែលលើកដៃមានកុមារខ្លះមានភាពក្លាហានច្រើនជាងកុមារដទៃទៀត ហើយបានឱ្យកុមារីម្នាក់ឡើងមកនិទានមុនគេ ដើម្បីធ្វើជាគំរូល្អដល់កុមារឡើងមកនិទានបន្ទាប់។ ពេលគាត់ឡើងនិទាន ភាគច្រើនគាត់ធ្វើបានល្អ តែមានផ្នែកខ្លះគាត់បានភ្លេចសាច់រឿង ដូច្នេះគ្រូបានជួយបន្ថែម។ បន្ទាប់ពីនិទានចប់ គ្រូ និងកុមារដទៃបានទះដៃលើកទឹកចិត្ត ហើយកុមារនិទានបានត្រឡប់មកកន្លែងវិញដោយភាពសប្បាយរីករាយ និងទំនុកចិត្ត។

កុមារទី២ឡើងនិទាន តែគាត់មិនមែននិទានរឿង ពពែវៃឆ្លាតនោះទេ គឺគាត់និទានរឿងផ្សេងដែលគាត់ចេះចាំពោរពេញដោយទំនុកចិត្ត។ គ្រូមិនបានបង្អាក់ការនិទានរបស់គាត់ទេ ដោយទុកឱ្យគាត់បាននិទានរហូតដល់ចប់។ គ្រប់គ្នាបានទះដៃលើកទឹកចិត្ត ហើយត្រឡប់ទៅកន្លែងវិញដោយភាពរីករាយ។

សម្រាប់កុមារទី៣ គ្រូចង់ឱ្យកុមារដែលមិនសូវមានទំនុកចិត្តបានឡើងនិទានដូចមិត្តភក្ដិដែរ។ គ្រូជ្រើសរើសកុមារម្នាក់ដែលមានការអៀនខ្លាំង និងមិនសូវចាំសាច់រឿងនោះទេ ដោយហៅគាត់មកក្បែរ ហើយនិយាយជាមួយគាត់ថា«អ្នកគ្រូនឹងជួយកូនឱ្យនិទានរឿងបានល្អ»។ កុមារហាក់ដូចជាមានទំនុកចិត្តជាងមុនបានសាកល្បងនិទាន។ ពេលគាត់និទាន គាត់ភ្លេចសាច់រឿងជាច្រើន គាត់និទានបានពីរទៅបីឃ្លា ក៏ឈប់ ដូច្នេះ គ្រូ និងកុមារដទៃបានជួយប្រាប់ ធ្វើឱ្យគាត់អាចនិទានរហូតដល់ចប់។ គ្រប់គ្នាទះដៃអបអរសាទរ។



កុមារទី២ឡើងមកនិទានរឿង



អ្នកគ្រូបើកសៀវភៅរូបភាពជាជំនួយដល់កុមារទី៣

Scanned with MOBILE SCANNER

## គន្លឹះបន្ថែម

### ការភ្ជាប់សកម្មភាពជាច្រើនតគ្នាបន្ទាប់ពីរឿងនិទាន

កុមារតូចចូលចិត្តធ្វើសកម្មភាពដដែលៗ លើប្រធានបទដែលគេកំពុងចូលចិត្តរហូតមានអារម្មណ៍ថាបានលេងឆ្អែត ហើយការលេងមានការវិវត្តទៅជាសកម្មភាពផ្សេងៗផងដែរ។ ឧទាហរណ៍ ពេលកុមារកំពុងចាប់អារម្មណ៍ លើដីខ្សាច់ ដំបូងគេលេងសាងសង់ភ្នំ តែក្រោយមកគេលេងជីកដីជាមួយរថយន្ត លេងចាក់ពុម្ពធ្វើនំ ឬលេងគូររូបលើដីខ្សាច់ជាដើម។ ការធ្វើសកម្មភាពជាច្រើនមានទំនាក់ទំនងតគ្នាពង្រីកការរៀនសូត្ររបស់កុមារឱ្យបានទូលំទូលាយប្រកបដោយភាពសប្បាយរីករាយ និងមានភាពទាក់ទាញ។

ខាងក្រោមនេះជាសកម្មភាពតភ្ជាប់ជាច្រើន ដែលបានអនុវត្តន៍ដោយគ្រូមត្តេយ្យសិក្សា ក្នុងករណីសិក្សាមួយរបស់គម្រោងអប់រំកុមារតូច ដោយអង្គការសន្តិស្ម័គ្រចិត្ត(SVA) ក្នុងខេត្តបាត់ដំបង។

១.លំហូរសកម្មភាពសំខាន់ៗ៖

**១.និទានរឿង**



**២.រំឭករឿងនិទាន**



**៣.គូររូបតាមសាច់រឿង**



**៥.ល្បែងបេះផ្លែស្វាយ**



**៤.ផលិតមកុដ**



**សង្ខេបរឿង ដំណើរផ្សងព្រេងរបស់ផេនដាសុភា**




ផេនដាសុភា បានធ្វើដំណើរទៅបេះផ្លែស្វាយដ៏មានឱជារស នៅឯភ្នំដ៏សែនឆ្ងាយ។ ផេនដាសុភា បានខ្ចីកង់ប្អូនស្រីសុភីជិះទៅបេះផ្លែស្វាយ ក៏បានជួបប្រទះឧបសគ្គជាច្រើនដូចជា អន្ទាក់របស់ចចក។ ផេនដាបានទៅដល់ដើមស្វាយ តែមិនចេះឡើងដើមស្វាយ។ ស្វាបានបង្រៀនផេនដាសុភាឱ្យចេះឡើងដើមស្វាយ និងបានខ្ចីកង់ផេនដាជិះចេញទៅ។ ស្វាបានជិះកង់ចេញទៅយ៉ាងយូរ មិនឃើញត្រឡប់មកវិញ ដូច្នេះផេនដាក៏ដើរត្រឡប់មកផ្ទះវិញជាមួយផ្លែស្វាយ។ តាមផ្លូវគាត់ត្រូវឱ្យផ្លែស្វាយដល់សត្វគោ និងអណ្តើកដែលបានជួយយកអាសា។ បន្ទាប់មកផេនដាបានជួបទន្សាយដ៏ស្រេកឃ្លានមួយក៏បានឱ្យផ្លែស្វាយចុងក្រោយទៅទន្សាយ ទីបំផុតផេនដាមកដល់ផ្ទះ ដោយគ្មានផ្លែស្វាយមកជាមួយ។ សំណាងល្អស្វាបានយកកង់ និងផ្លែស្វាយមួយត្រកជូនផេនដាសុភា និងគ្រួសារបានពិសារយ៉ាងរីករាយ។

| សកម្មភាពប្រចាំថ្ងៃ (២០១៦) | |
|---|---|
| ម៉ោង | សកម្មភាព |
| ៧:០០-៧:៣០ | សកម្មភាពថ្ងៃចន្ទ ទី៧ |
| ៧:៣០-៨:០០ | និទានរឿង |
| ៨:០០-៨:១០ | ចេញលេង |
| ៨:១០-៨:៥០ | រំឭកតួអង្គ និងគំនូរ(សិក្សាសង្គម) |
| ៨:៥០-៩:០០ | ចេញលេង |
| ៩:០០-៩:៣០ | ផលិតមកុដ(សិក្សាសង្គម) |
| ៩:៣០-១០:១៥ | ល្បែងបេះផ្លែស្វាយ(ចិត្តចលភាព) |
| ១០:១៥-១០:៣០ | រំឭកមេរៀន |

<u>បញ្ជាក់៖</u>

- ដោយសារសាលាមត្តេយ្យនៅជាមួយបឋមសិក្សា ការរៀបចំផែនការបង្រៀនប្រចាំថ្ងៃគ្រូត្រូវមានភាពបត់បែនតាមស្ថានភាពជាក់ស្តែង ដូច្នេះការអនុវត្តមិនបានតាមកាលវិភាគនេះទាំងស្រុងទេ។
- គ្រូក៏អាចដំណើរការសកម្មភាពនេះក្នុងរយៈពេល២ថ្ងៃបន្តបន្ទាប់ក្នុងផែនការបង្រៀន។

Scanned with MOBILE SCANNER

២. ដំណើរការសកម្មភាព

**ការនិទានរឿង**

- ដំបូង គ្រូនិទានរឿងផេនដាសុភា ឱ្យកុមារស្តាប់ប្រកបដោយសេចក្តីស្រឡាញ់ និងភាពស្និទ្ធស្នាល។

**រំលឹកតួអង្គ និងចែកក្រុមកុមារដើម្បីលេងល្បែង**

- បន្ទាប់ពីនិទានរឿងរួច គ្រូសួរកុមារថាតើមានតួអង្គអ្វីខ្លះនៅក្នុងរឿងផេនដាសុភា។ ចម្លើយមានដូចជា ផេនដា ស្វា ទន្សាយ គោ អណ្តើក និងចចក។
- គ្រូបិទរូបតួអង្គសត្វខាងលើនៅលើក្តារខៀន។
- គ្រូចែកកុមារជាក្រុមទៅតាមប្រភេទសត្វដែលកុមារបានឆ្លើយ(ក្រុមផេនដា ស្វា ទន្សាយ និងគោ)។

**គំនូរសេរី**

- គ្រូលើកទឹកចិត្តឱ្យកុមារគូររូបសត្វក្នុងសាច់រឿងដោយសេរី តាមការស្រមើស្រមៃពីសាច់រឿង។



**ផលិតមកុដ៖**

- គ្រូកាត់ក្រដាសកាតុងជារាងមកុដរួចជាស្រេច។
- កុមារកាត់រូបគំនូររបស់ខ្លួនមកបិទលើមកុដ។
- គ្រូកិបភ្ជាប់ធ្វើមកុដតាមទំហំក្បាលរបស់កុមារនីមួយៗ។

**ល្បែង«បេះផ្លែស្វាយ»**

- កុមារពាក់មកុដរបស់ខ្លួនចូលលេងល្បែងបេះផ្លែស្វាយ ដោយដើរតួជាផែនដាសុភារត់ទៅបេះផ្លែស្វាយ
- គ្រូពាក់មកុដជារូបចចកដេញចាប់កុមារ ប៉ុន្តែធ្វើពុតជាចាប់មិនបានដើម្បីផ្តល់ឱកាសឱ្យកុមារបេះផ្លែស្វាយបាន។




__របៀបលេងល្បែងបេះផ្លែស្វាយ__

លក្ខខណ្ឌ៖ ល្បែងនេះជាការប្រកួតរវាងក្រុម និងក្រុម ចាប់ពីពីរក្រុមឡើងទៅ លេងម្តងមួយក្រុម។ កុមារដើរតួជាខ្លាឃ្មុំផេនដាសុភា រីឯគ្រូដើរតួជាចចក។ កុមារព្យាយាមរត់ទៅរើសផ្លែស្វាយមកដាក់កន្ត្រក ធ្វើយ៉ាងណាកុំឱ្យចចកចាប់បាន ក្នុងពេលកំណត់ណាមួយ។ កុមារអាចរើសផ្លែស្វាយបានច្រើន ប៉ុន្តែរត់ទៅម្តងរើសបានតែមួយផ្លែប៉ុណ្ណោះ។ កុមារដែលត្រូវចចកចាប់បាន យកទៅដាក់ក្នុងទ្រុង មិនអនុញ្ញាតឱ្យលេងទៀតទេ។ ក្រុមណាដែលរើសផ្លែស្វាយបានច្រើនជាងគេជាអ្នកឈ្នះ។

**តើកុមារបានអភិវឌ្ឍន៍អ្វីខ្លះពីសកម្មភាពទាំងនេះ?**

| វិស័យសំខាន់ៗទាំង៥ | ការអភិវឌ្ឍ |
|---|---|
| ការអភិវឌ្ឍរូបរាងកាយ និងសុខភាព  | - អភិវឌ្ឍន៍រូបរាងកាយតាមរយៈការលេងល្បែងចលនា មានចលនាធំ (បេះផ្លែស្វាយជាដើម)<br>- ធ្វើចលនាម្រាមដៃ ចលនាតូច (កាន់ប៊ិក ខ្មៅដៃ គូររូប ធ្វើក្បាំងមុខជាដើម<br>- មានភាពរហ័សរហួនពេលរត់ទៅបេះផ្លែស្វាយ។ |
| ការអភិវឌ្ឍសីលធម៌ និងវប្បធម៌  | - រៀនសូត្រពីការគោរពលក្ខខណ្ឌ ចេះជួយទុក្ខធុរៈ<br>- សម្របសម្រួលខ្លួនជាមួយមិត្តភក្តិ។ |
| ការអភិវឌ្ឍសង្គម និងអារម្មណ៍  | - សហការ និងមានទំនាក់ទំនងជាមួយមិត្តភក្តិ<br>- មានអារម្មណ៍សប្បាយពេលលេងជាមួយគ្នា<br>- ស្វែងយល់អារម្មណ៍អ្នកដទៃពេលស្តាប់រឿងនិទាន<br>- មានអារម្មណ៍ស្និទ្ធស្នាលជាមួយគ្រូនៅពេលស្តាប់ រឿងនិទាន។ |
| ការអភិវឌ្ឍការយល់ដឹង និងការពិចារណា  | - យល់ពីខ្លឹមសាររបស់រឿងនិទានទាំងមូល លំហូរ ឬលំដាប់លំដោយនៃសកម្មភាព<br>- យល់ពីខ្លឹមសាររាប់ ចំនួន<br>- សិល្បៈច្នៃប្រឌិតតាមរយៈការគូររូបភាព និងផលិតមកុដ<br>- សមត្ថភាពនៃការគិតពិចារណា និងស្រមើស្រមៃ (ឧទាហរណ៍ កុមាររំឭករឿងសារឡើងវិញពេលគ្រូឱ្យជ្រើសរើសតួអង្គសត្វ។ |
| ការអភិវឌ្ឍភាសា  | - កុមាររីកចម្រើនការស្តាប់ និងពាក្យពេចន៍តាមរយៈការនិទានរឿង<br>- កាន់តែចាប់អារម្មណ៍លើការអានសៀវភៅ<br>- ជជែកជាមួយគ្រួសារ និងមិត្តភក្តិបន្ទាប់ពីធ្វើសកម្មភាពនេះនៅសាលារៀន។ |

Scanned with MOBILE SCANNER



# ជំពូកទី៥

## ការលើកកម្ពស់ការអាននៅផ្ទះ

Scanned with MOBILE SCANNER

កុមារតូចចូលចិត្តស្តាប់ និងអានរឿងនិទាន។ តាមរយៈការស្តាប់ និងអាននេះធ្វើឱ្យកុមារទទួលបាននូវចំណេះដឹងពីអ្វីៗដែលមាននៅជុំវិញខ្លួន និងនៅលើពិភពលោក។ ក្នុងវ័យនេះ កុមារតូចមានការរីកលូតលាស់ខួរក្បាលខ្លាំង ជួយឱ្យមានការអភិវឌ្ឍផ្នែកភាសា និងមានការស្រមើស្រមៃខ្ពស់។

តើយើងអាចធ្វើអ្វីបានខ្លះដើម្បីជំរុញដល់ការអានរបស់កុមារ? ជាការពិតណាស់ សាលារៀនបានរៀបចំឱ្យមានសកម្មភាពអភិវឌ្ឍការអានរបស់កុមារដូចជាការនិទានរឿង ការអានសេរីជាដើម។ បន្ថែមពីលើនេះទៀត ការរៀបចំបរិស្ថានអំណោយផលដល់ការអានរបស់កុមារនៅផ្ទះក៏មានសារៈសំខាន់ផងដែរ។

## ១. សារៈសំខាន់នៃការអាននៅផ្ទះ

កុមារចូលចិត្តស្តាប់រឿងនិទានពីអ្នកដែលគាត់នៅស្និទ្ធស្នាលជាមួយ។ កុមារចូលចិត្តមើល និងអានរឿងតាមរូបភាព ហើយទទួលបាននូវអារម្មណ៍ផ្សេងៗ បើទោះបីជាពួកគេមិនចេះអានអក្សរក៏ដោយ។ មាតាបិតា ឬអ្នកថែទាំកុមារមួយចំនួនអាចមានការលំបាកក្នុងការអានសៀវភៅ តែមិនចាំបាច់បារម្ភទេ។ មាតាបិតាគ្រាន់តែមើលសៀវភៅជាមួយកុមារ ចែករំលែកភាពរីករាយ និងនិយាយជាមួយគ្នា។ អ្វីដែលសំខាន់គឺការប្រាស្រ័យទាក់ទងជាមួយកុមារ និងឈានទៅរកភាពស្និទ្ធស្នាលនៅក្នុងគ្រួសារ។ ចុងក្រោយ កុមារនឹងកាន់តែចូលចិត្តសៀវភៅរូបភាព រីកចម្រើនផ្នែកភាសា និងបណ្តុះបានជាទម្លាប់នៃការអានសៀវភៅ។

### គន្លឹះគួរចងចាំ

- ការនិទានរឿងមិនទាមទារមានបច្ចេកទេសពិសេសអ្វីនោះទេ។ អ្វីដែលសំខាន់គឺកុមារអាចរីករាយនឹងការនិទានរឿងជាមួយមនុស្សជាទីស្រលាញ់របស់ខ្លួនជាជាងអានឱ្យបានត្រឹមត្រូវតាមសាច់រឿង។
- មាតាបិតា អាណាព្យាបាល និងកូនរបស់ខ្លួនគ្រាន់តែរីករាយក្នុងការអានសៀវភៅរូបភាពជាមួយគ្នាគឺគ្រប់គ្រាន់ហើយ។
- សៀវភៅរូបភាពមិនមែនសម្រាប់រៀនអក្សរ ឬអ្វីឡើយ។ សូមឱ្យកុមាររីករាយនឹងពិភពនៃរឿងនិទាន ចៀសវាងសួរពីនេះ ពីនោះក្នុងពេលនិទាន ឬអានរឿង។
- សូមឱ្យមាតាបិតា អាណាព្យាបាលអាន ឬនិទានរឿងឱ្យកូនរបស់ខ្លួន ទោះបីជាក្នុងរយៈពេលខ្លី ឬមិនបានជាប្រចាំក៏ដោយ ដូចជាមុនពេលចូលគេងជាដើម។



### តើកុមារអភិវឌ្ឍភាសាដោយរបៀបណា?




កុមាររៀនភាសាពីបរិស្ថានរបស់ខ្លួន ដូច្នេះការអប់រំ ការថែទាំ និងទំនាក់ទំនងមានសារៈសំខាន់ទាំងនៅសាលារៀន និងនៅផ្ទះដូចគ្នា។

Scanned with
MOBILE SCANNER

## ២. ការរៀបចំរុញការអាននៅផ្ទះ

មានវិធីសាស្ត្រជាច្រើនក្នុងការបណ្ដុះទម្លាប់កុមារអាននៅផ្ទះ ដូចជាតាមរយៈការខ្ចី សងសៀវភៅអានពីថ្នាក់មត្តេយ្យសិក្សា ឬបណ្ណាល័យ ការទិញសៀវភៅពីផ្សារ និងប្រភពផ្សេងៗទៀត។

### ២.១. ការខ្ចីសៀវភៅពីថ្នាក់មត្តេយ្យ បណ្ណាល័យសាលារៀន បណ្ណាល័យសាធារណៈ

តើយើងអាចជំរុញឱ្យមាតាបិតាខ្ចីសៀវភៅទៅអាននៅផ្ទះដោយរបៀបណា? ដំបូង ធ្វើឱ្យកុមារចាប់អារម្មណ៍លើសៀវភៅរូបភាព។ ដូចនេះ ការនិទានរឿងនៅក្នុងថ្នាក់រៀនគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ។ វាក៏មានសារៈសំខាន់ដែលអ្នកថែទាំកុមារមានអារម្មណ៍ថា «ខ្ញុំចង់ខ្ចីសៀវភៅអានឱ្យកូនខ្ញុំស្ដាប់!»។សូមពន្យល់ពីអត្ថប្រយោជន៍នៃការនិទានរឿង និងការអានសៀវភៅនៅផ្ទះ។ បន្ទាប់មកយើងអាចពន្យល់ពីការខ្ចីសៀវភៅ។ យើងអាចណែនាំសៀវភៅល្អៗឱ្យពួកគាត់បានស្គាល់ ឬសៀវភៅដែលយើងប្រើប្រាស់ក្នុងថ្នាក់រៀន។

**គន្លឹះគួរចងចាំ**

- រៀបចំការនិទានរឿងនៅក្នុងថ្នាក់។ លើកទឹកចិត្តឱ្យកុមារអានសៀវភៅនៅផ្ទះ
- ពន្យល់អ្នកថែទាំកុមារអំពីសារៈសំខាន់នៃការនិទានរឿង និងការអាននៅផ្ទះ
- ផ្សព្វផ្សាយពីការខ្ចីសៀវភៅដល់អ្នកថែទាំកុមារ (របៀបខ្ចី ទីកន្លែង បទបញ្ជាផ្សេងៗ)
- ណែនាំសៀវភៅល្អៗឱ្យពួកគាត់បានស្គាល់ ឬសៀវភៅដែលយើងប្រើប្រាស់ក្នុងថ្នាក់រៀន
- ជ្រើសរើសសៀវភៅសមស្របតាមវ័យរបស់កុមារ។

ក្រៅពីបណ្ណាល័យសាលាមត្តេយ្យសិក្សា យើងមានបណ្ណាល័យផ្សេងៗទៀតដែលបើកទូលាយសម្រាប់អ្នកអានក្នុងសហគមន៍ ដូចជាបណ្ណាល័យក្នុងសាលាបឋមសិក្សា បណ្ណាល័យសាធារណៈ ឬបណ្ណាល័យសហគមន៍ជាដើម។ គ្រូមត្តេយ្យសិក្សាចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកថែទាំកុមារតូចបានដឹងពីព័ត៌មានពីបណ្ណាល័យ និងលើកទឹកចិត្តឱ្យគាត់បានខ្ចីសៀវភៅទៅអានឱ្យកូនស្ដាប់បន្ថែមទៀតនៅផ្ទះ។ បើមានលទ្ធភាព សាលាបង្កើតប័ណ្ណផ្សព្វផ្សាយព័ត៌មានផ្សេងៗសម្រាប់ជំនួយដល់ការពន្យល់ដល់អ្នកថែទាំកុមារ។ ខាងក្រោមជាឧទាហរណ៍ប័ណ្ណផ្សព្វផ្សាយការអាន និងការខ្ចី សងសៀវភៅសម្រាប់សាលារៀន។



**ប័ណ្ណផ្សព្វផ្សាយការអាន**




**ការរៀបចំកន្លែងដាក់តាំងសៀវភៅសម្រាប់អ្នកអាណាព្យាបាលកុមារខ្ចីទៅអាននៅផ្ទះ**



នៅពេលមាតាបិតាអ្នកអាណាព្យាបាលបានយល់ដឹងពីសារៈសំខាន់នៃការអាននៅផ្ទះរបស់កុមារ គ្រូគួរយកចិត្តទុកដាក់ផ្ដល់ភាពងាយស្រួលដល់ពួកគាត់បានប្រើប្រាស់សៀវភៅក្នុងថ្នាក់មត្តេយ្យឱ្យកាន់តែមានប្រសិទ្ធភាព។ គ្រូរៀបចំកន្លែងពិសេសមួយ ដាក់តាំងសៀវភៅសម្រាប់អ្នកអាណាព្យាបាល ដោយជ្រើសរើសទីតាំងនៅក្បែរទ្វារ ឬបរិវេណខាងមុខថ្នាក់។ សៀវភៅទាំងនោះទាក់ទងនឹងសកម្មភាពបង្រៀនដែលកុមារកំពុងចាប់អារម្មណ៍ ដូចជាសៀវភៅរឿង សៀវភៅវិទ្យាសាស្ត្រ សៀវភៅទាក់ទងនឹងបុណ្យប្រពៃណី និងរដូវកាលជាដើម។ នៅក្បែរនោះគ្រូរៀបចំបញ្ជីខ្ចី សងសៀវភៅសម្រាប់ពួកគាត់ចុះកំណត់ត្រាខ្ចី សងដោយខ្លួនឯង។

Scanned with MOBILE SCANNER

## ២.២. ការរកសៀវភៅពីកន្លែងផ្សេងៗ

ក្រៅពីបណ្ណាល័យខាងលើ អ្នកថែទាំកុមារមានជម្រើសស្វែងរកសៀវភៅពីប្រភពផ្សេងៗទៀតបាន ដូចជាការទិញពីទីផ្សារដោយខ្លួនឯង បណ្ណាល័យអេឡិចត្រូនិចពីគេហទំព័រផ្សេងៗដោយឥតគិតថ្លៃ តាមរយៈទូរស័ព្ទដៃ ឬកុំព្យូទ័រ តាមលទ្ធភាពរៀងៗខ្លួន។ បណ្ណាល័យអេឡិចត្រូនិចខាងក្រោមនេះមិនបង្កើតឡើងដើម្បីរកប្រាក់កម្រៃនោះទេ ហើយយើងអាចទាញយកទិន្នន័យមករក្សាទុកបាន ដោយអនុវត្តន៍តាមវិន័យ និងបទបញ្ញារបស់បណ្ណាល័យ។

### ២.២.១. បណ្ណាល័យអេឡិចត្រូនិចរបស់អង្គការសន្តិស្ម័គ្រចិត្ត(SVA)




បណ្ណាល័យអេឡិចត្រូចនិចរបស់អង្គការសន្តិស្ម័គ្រចិត្ត(SVA) ផ្តល់ជូននូវវីដេអូនៃការនិទានរឿង និងសៀវភៅរូបភាពអេឡិចត្រូនិចដើម្បីឱ្យកុមារ និងមនុស្សធំបានអានរឿងនិទាននៅគ្រប់ទីកន្លែង។ រឿងនិទានដែលដាក់ចូលក្នុងបណ្ណាល័យនេះជាប្រភេទរឿងនិទានខ្មែរ ជាភាសាខ្មែរ បោះពុម្ពដោយអង្គការសន្តិស្ម័គ្រចិត្ត។ សូមចូលមើលបណ្ណាល័យតាមរយៈគេហទំព័រ៖ https://svacamelib.org/ ។

### ២.២.២. បណ្ណាល័យអេឡិចត្រូនិច Let's Read




«Let's Read គឺជាកិច្ចផ្តួចផ្តើមរបស់កម្មវិធីសៀវភៅសម្រាប់អាស៊ីនៃអង្គការមូលនិធិអាស៊ី ដែលជំរុញអ្នកអានវ័យក្មេងក្នុងអាស៊ី។ បណ្ណាល័យនេះប្រមូលផ្តុំសៀវភៅរឿងឌីជីថល ដែលមានគុណភាពខ្ពស់ ជាភាសាជាតិ និងភាសាជនជាតិដើម។» បណ្ណាល័យនេះមានសៀវភៅច្រើនភាសា តាមការជ្រើសរើសរបស់អ្នកអានតាមកម្រិតថ្នាក់។ សូមស្វែងរកបន្ថែមតាមរយៈគេហទំព័រ https://reader.letsreadasia.org/។ យើងក៏អាចទាញយកកម្មវិធីបណ្ណាល័យនេះពី Play Store របស់ប្រព័ន្ធAndroid តាមទូរស័ព្ទដៃទំនើបបានផងដែរ។




Literacy Cloud គឺជាគេហទំព័រ និងសេវាកម្មដែលផ្តល់ជូនដោយ រូមធូរីដ ដែលជាអង្គការមិនស្វែងរកប្រាក់ចំណេញ។ បណ្ណាល័យមានរឿងនិទានជាច្រើនចំណងជើង ច្រើនភាសា រួមទាំងភាសាខ្មែរផងដែរតាមកម្រិតថ្នាក់ និងវីដេអូអានរឿងដោយបុគ្គលិករូមធូរីដ។ សូមស្វែងរកបន្ថែមតាមរយៈគេហទំព័រ៖ https://literacycloud.org និងជ្រើសរើសយកភាសាខ្មែរ។

## ២.៣. ព្រឹត្តិការណ៍ជំរុញការអាននៅផ្ទះ

ព្រឹត្តិការណ៍ជំរុញការអានជាសកម្មភាពដែលរៀបចំឡើងរបស់សាលាដើម្បីផ្សព្វផ្សាយបញ្ជ្រាបពីសារៈសំខាន់នៃការអានសៀវភៅសម្រាប់កុមារតូច។ ព្រឹត្តិការណ៍នេះមិនចាំបាច់រៀបចំដាច់ដោយឡែកនោះទេ។ យើងបញ្ចូលជាមួយព្រឹត្តិការណ៍ប្រចាំឆ្នាំរបស់សាលាដូចជា ទិវាបើកបវេស្សនកាល ទិវាជាតិអំណាន ទិវាកុមារអន្តរជាតិ កម្មវិធីវិស្សមកាលចុងឆ្នាំជាដើម។

គន្លឹះរៀបចំព្រឹត្តិការណ៍ជំរុញការអាននៅផ្ទះ៖

- <u>ក្រុមគោលដៅ៖</u> កុមារ មាតាបិតា ឬអ្នកអាណាព្យាបាល។
- <u>កម្មវិធី៖</u> មានបញ្ចូលពីសារៈសំខាន់នៃការអានទូទៅ និងអាននៅផ្ទះ សកម្មភាពបណ្ណាល័យក្នុងសាលា ការនិទានរឿងដោយគ្រូ បណ្ណារក្ស ឬកុមារ សកម្មភាពធ្វើឱ្យមាតាបិតា ឬអ្នកអាណាព្យាបាលបានរីករាយនឹងការអានសៀវភៅជាមួយកុមារ។
- <u>ឧបករណ៍ផ្សព្វផ្សាយ៖</u> តាមលទ្ធភាពរបស់សាលា រៀបចំឱ្យមានផ្ទាំងបដាផ្សព្វផ្សាយ ពាក្យស្លោក ខិត្តប័ណ្ណផ្សព្វផ្សាយព័ត៌មានអប់រំផ្សេងៗទាក់ទងនឹងការអាន។

PDF Scanned with MOBILE SCANNER

## ឧទាហរណ៍

បទពិសោធរៀបចំព្រឹត្តិការណ៍ការជំរុញអំណានរបស់សាលាមត្តេយ្យសិក្សាធនធានក្រុងបាត់ដំបង ក្រុងបាត់ដំបង ខេត្តបាត់ដំបង៖






<u>សង្ខេបកម្មវិធី</u>

- បើកកម្មវិធី
- បទបង្ហាញការអភិវឌ្ឍភាសារបស់កុមារ ការអាន និងខ្ចីសៀវភៅ
- ការនិទានរឿងដោយគ្រូមត្តេយ្យសិក្សា
- អានសេរីរបស់កុមារ និងអាណាព្យាបាល
- ចែកប័ណ្ណព័ត៌មានស្ដីពីសារៈសំខាន់នៃការអប់រំកុមារតូច។



ការជំរុញអំណានរបស់កុមារជាផ្នែកមួយសំខាន់ដែលសាលាតែងតែផ្ដោតការយកចិត្តទុកដាក់។ គណៈគ្រប់គ្រងសាលាគិតថា កុមារនៅកម្រិតមត្តេយ្យសិក្សាអភិវឌ្ឍភាសាបានឆាប់រហ័សពីបរិស្ថាននៅជុំវិញខ្លួនទាំងនៅសាលារៀន និងនៅផ្ទះ។ ចាប់តាំងពីឆ្នាំ២០១៥មក សាលាបានរៀបចំជ្រុងសិក្សាក្នុងបន្ទប់ថ្នាក់មត្តេយ្យនីមួយៗ មានសៀវភៅគ្រប់គ្រាន់សម្រាប់កុមារអាន ឬខ្ចីទៅអាននៅផ្ទះ។ ដើម្បីជំរុញការអាននៅផ្ទះបន្ថែម និងបង្កើនទំនាក់ទំនងជាមួយអ្នកអាណាព្យាបាល សាលាបញ្ចូលខ្លឹមសារសារៈសំខាន់នៃការអានក្នុងទិវាបើកបវេសនកាល។

សាលាចង់ឱ្យមាតាបិតាបានយល់បន្ថែមពីសារៈសំខាន់នៃការអាន និងរបៀបដែលកុមារអភិវឌ្ឍភាសា។ មាតាបិតាប្រមាណ៧០នាក់បានចូលរួមស្ដាប់បទបង្ហាញ ការនិទានរឿងដោយគ្រូមត្តេយ្យសិក្សា និងសកម្មភាពអានសេរីជាមួយកូនរបស់ខ្លួន។ សាលាបានចែកប័ណ្ណព័ត៌មានស្ដីពីសារៈសំខាន់នៃការអប់រំកុមារតូច និងការខ្ចីសៀវភៅទៅអាននៅផ្ទះ។

បន្ទាប់ពីព្រឹត្តិការណ៍នេះមក មាតាបិតាសិស្សកាន់តែយល់ដឹងពីសារៈសំខាន់នៃការអប់រំកុមារតូច និងការខ្ចីសៀវភៅសម្រាប់កូនរបស់ខ្លួន។ ចំនួនមាតាបិតា អ្នកអាណាព្យាបាលខ្ចីសៀវភៅពីថ្នាក់មត្តេយ្យសិក្សានៅចុងម៉ោងសិក្សាកើនឡើងជាបន្តបន្ទាប់។ ពួកគាត់មួយចំនួនបានសួរទៅសាលាថា តើមានកង្វះខាតចំនួនសៀវភៅនៅក្នុងថ្នាក់ដែរ ឬទេ ហើយបើគាត់ចង់ទិញសៀវភៅដាក់ថ្នាក់មត្តេយ្យតើគួរទិញសៀវភៅប្រភេទណា។

លើសពីនេះ ការរៀបចំព្រឹត្តិការណ៍បែបនេះក៏ជួយបង្កើនទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ឱ្យកាន់តែប្រសើរឡើង។ សាលាបានទទួលការគាំទ្របន្ថែមពីសហគមន៍ រួមមានហិរញ្ញវត្ថុ សម្ភារ និងកម្លាំងពលកម្ម។




ការចែកប័ណ្ណផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំកុមារតូច (រូបទី១) និងសកម្មភាពអានសេរី (រូប២ ដល់៤)

Scanned with MOBILE SCANNER

## ឧទាហរណ៍

### បទពិសោធជំរុញការអានថ្នាក់មត្តេយ្យសិក្សានៅសាលាបឋមសិក្សាវត្តគរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

រូបថតចាំងពេក





បណ្ណាល័យជាផ្នែកមួយសំខាន់ក្នុងការអប់រំ និងបណ្ដុះទម្លាប់អានរបស់កុមារ ដូច្នេះហើយបានជាក្រសួងអប់រំ យុវជន និងកីឡា ចេញគោលការណ៍ណែនាំឱ្យគ្រប់សាលាបឋមសិក្សាទាំងអស់រៀបចំបណ្ណាល័យតាមលទ្ធភាពរបស់ខ្លួន។ ដោយឡែកសាលាមត្តេយ្យសិក្សា ការរៀបចំបណ្ណាល័យគឺអាស្រ័យតាមលទ្ធភាពជាក់ស្ដែងរបស់សាលា តែត្រូវរៀបចំជ្រុងសិក្សាសម្រាប់ដាក់សៀវភៅឱ្យកុមារបានអានសេរី។ បន្ទាប់ពីទទួលបានវគ្គបំប៉នជាច្រើន សាលាបឋមសិក្សាវត្តគរកាន់តែយល់ឃើញច្បាស់ថា ការអាននៅមត្តេយ្យសិក្សាពិតជាមានអត្ថប្រយោជន៍សម្រាប់កុមារតូច ជាពិសេសទៅលើការអភិវឌ្ឍភាសា។

ក្នុងសកម្មភាពបង្រៀន និងរៀនប្រចាំថ្ងៃ គ្រូមត្តេយ្យសិក្សារៀបចំសកម្មភាពរឿងនិទានជាញឹកញាប់ទាំងនៅក្នុងម៉ោងសិក្សា និងពេលមានសំណូមពរពីកុមារ។ បន្ទាប់ពីការនិទានរឿង កុមារតែងតែចង់អានសៀវភៅរឿងនោះនៅក្នុងថ្នាក់ ឬខ្ចីទៅផ្ទះ។ ដំបូងឡើយ គ្រូមានភាពស្ទាក់ស្ទើរនឹងបើកដំណើរការខ្ចី សងសៀវភៅដល់កុមារ ដោយបារម្ភថាកុមារនៅតូច មិនទាន់ចេះគ្រប់គ្រងសៀវភៅ ធ្វើឱ្យរហែក និងបាត់បង់សៀវភៅជាដើម។ ដោយមានការលើកទឹកចិត្តពីមជ្ឈដ្ឋានជុំវិញ និងយល់ដឹងពីសារៈសំខាន់នៃការអាននៅផ្ទះរបស់កុមារ គ្រូបានសាកល្បងឱ្យកុមារខ្ចី។ គ្រូបានរៀបចំបញ្ជីផ្សេងៗដើម្បីគ្រប់គ្រងសៀវភៅ រួមទាំងបញ្ជីខ្ចីសង។ ជាញឹកញាប់ គ្រូច្រើនឱ្យកុមារខ្ចីនៅពេលនិទានរឿងរួច ព្រោះកុមារកំពុងតែចាប់អារម្មណ៍សៀវភៅខ្លាំង។ គ្រូអនុញ្ញាតឱ្យកុមារខ្ចីនៅថ្ងៃពុធ និងថ្ងៃសៅរ៍ ដោយសារថ្ងៃបន្ទាប់ជាថ្ងៃសម្រាក ដូច្នេះកុមារមានពេលអានច្រើន តែពេលខ្ចីត្រូវមានអាណាព្យាបាលមកជាមួយ។

ទន្ទឹមគ្នានេះ គ្រូបានជួបប្រទះការលំបាកមួយចំនួន ព្រោះកុមារខ្លះនៅមិនទាន់ចេះថែទាំ និងសងសៀវភៅមកវិញយឺត។ ពេលខ្លះគ្រូមិនប្រាកដថា តើមានអ្នកណាជាអ្នកអានសៀវភៅជាមួយកុមារនៅផ្ទះ។ ផ្ទុយទៅវិញ ក៏មានកុមារមួយចំនួនបានសងសៀវភៅមកវិញបានត្រឹមត្រូវតាមពេលវេលាកំណត់ និងថែទាំបានល្អផងដែរ។ កុមារខ្លះបាននិយាយទៅកាន់ឪពុកម្ដាយខ្លួនថា«អ្នកគ្រូអូនឱ្យអូនថែទាំសៀវភៅឱ្យបានល្អ បើកថ្នមៗ កុំឱ្យប្រឡាក់ កុំឱ្យរហែក»។ ការងារដែលគ្រូត្រូវធ្វើជាប្រចាំគឺពិនិត្យតាមដានការខ្ចី សងសៀវភៅរបស់កុមារ និងលើកទឹកចិត្តអាណាព្យាបាលខ្ចីសៀវភៅឱ្យបានច្រើន។



បន្ទាប់ពីដំណើរការខ្ចីសៀវភៅមួយរយៈ គ្រូសង្កេតឃើញថា កុមារស៊ាំនឹងការខ្ចីសៀវភៅ កាន់តែចូលចិត្តសៀវភៅ និងចេះចុះហត្ថលេខាលើបញ្ជីខ្ចី សងសៀវភៅបានដោយខ្លួនឯង។ កុមារមួយចំនួនចេះប្រើពាក្យពេចន៍ ឃ្លាល្បះច្រើនជាងអ្វីដែលគាត់ប្រើប្រាស់ប្រចាំថ្ងៃ ដោយសារកុមារបានស្ដាប់រឿងនិទានដោយគ្រូ ឬអាណាព្យាបាលច្រើន។ អ្នកអាណាព្យាបាលមួយចំនួនដឹងថាកូនរបស់ខ្លួនចូលចិត្តសៀវភៅ និងសាលារៀនត្រូវការសៀវភៅថ្មីបន្ថែម ដូច្នេះពួកគាត់បានឧបត្ថម្ភថវិកាទិញសៀវភៅដាក់នៅជ្រុងបណ្ណាល័យ។ ក្នុងផែនការអភិវឌ្ឍប្រចាំឆ្នាំ សាលារៀនបានគ្រោងថវិកាទិញសៀវភៅមួយចំនួនសម្រាប់ថ្នាក់មត្តេយ្យផងដែរ។

ជាចុងក្រោយ គ្រូមត្តេយ្យសិក្សាបានបញ្ជាក់ថា «យើងទទួលស្គាល់ថា ការខ្ចី សងសៀវភៅជាបរិបទថ្មីមួយសម្រាប់មត្តេយ្យសិក្សា និងបន្ថែមការងារដល់គ្រូផងដែរ។ ប៉ុន្តែតាមរយៈលទ្ធផលខាងលើ យើងខ្ញុំសូមលើកទឹកចិត្តគ្រូមត្តេយ្យសិក្សាអនុវត្តការខ្ចីសងសៀវភៅឱ្យបានច្រើន។»



កុមារអានសៀវភៅនៅផ្ទះជាមួយម្ដាយ

Scanned with MOBILE SCANNER

## ឧទាហរណ៍

### បទពិសោធការអាននៅផ្ទះរបស់មាតាបិតាសិស្ស



លោកស្រី«ក»មានកូន១នាក់រៀននៅមត្តេយ្យសិក្សាកម្រិតខ្ពស់។ លោកស្រីបានបញ្ជូនកូនទៅរៀនមត្តេយ្យសិក្សាតាំងពីអាយុ៣ឆ្នាំ ព្រោះគាត់យល់ថាការរៀននៅមត្តេយ្យសិក្សាពិតជាមានសារៈសំខាន់ណាស់។ ពេលទទួលកូនចេញពីសាលា អ្នកគ្រូបានប្រាប់ថា នៅក្នុងថ្នាក់មត្តេយ្យសិក្សា និងបណ្ណាល័យមានសៀវភៅរឿងជាច្រើន ដែលមាតាបិតាអាចខ្ចីយកទៅអាននៅផ្ទះបាន។ ដំបូងគាត់មិនសូវចាប់អារម្មណ៍ទេ ដោយសារតែគិតថាកូននៅតូច មិនអាចអានសៀវភៅបានទេ ហើយលោកស្រីខ្លួនឯងផ្ទាល់ក៏មិនសូវចូលចិត្តអានសៀវភៅដែរព្រោះរវល់លក់ដូរនៅផ្ទះ។

ថ្ងៃមួយ កូនប្រាប់ថា«ម៉ាក់អ្នកគ្រូអូនឱ្យខ្ចីសៀវភៅយកទៅអាននៅផ្ទះបាន តែម៉ាក់ត្រូវទៅខ្ចីជាមួយអូន»។ លោកស្រីមិនប្រកែក ហើយជូនកូនទៅខ្ចីសៀវភៅ១ក្បាល ដោយចុះហត្ថលេខាលើបញ្ជីខ្ចី សងសៀវភៅ។ គាត់បានបន្តខ្ចីសៀវភៅពីសាលាមួយរយៈ។ បន្ថែមពីនេះទៅទៀត គាត់ចូលចិត្តស្រាវជ្រាវរកសៀវភៅរឿងសម្រាប់កុមារតាមទូរស័ព្ទដៃ អានជាមួយកូន។ ខាងក្រោមជាលទ្ធផលដែលលោកស្រីទទួលបានពីការអាននៅផ្ទះជាមួយកូន៖

«ខ្ញុំមានអារម្មណ៍សប្បាយរីករាយដែលឃើញកូនចូលចិត្តអានសៀវភៅ។ កូនខ្ញុំចូលចិត្តមើលសៀវភៅរឿងមានរូបភាពច្រើន ជាពិសេសរឿងដែលអ្នកគ្រូបាននិទាននៅសាលារៀន។ គាត់តែងតែឱ្យខ្ញុំអានរឿងនៅពេលយប់មុនចូលគេង។ ថ្ងៃខ្លះ ខ្ញុំអស់កម្លាំង តែដោយសារកូនសំណូមពរ ខ្ញុំព្យាយាមអានឱ្យគាត់ស្ដាប់ អានបណ្ដើរធ្លាក់សៀវភៅពីដៃក៏មានដែរ។ ភ្លាមនោះកូនសួរថា «យ៉ាងម៉ិចហើយម៉ាក់?» ហើយខ្ញុំស្ទុះយកសៀវភៅមកកាន់អានបន្តរហូតដល់ចប់។ បើថ្ងៃណាខ្ញុំមិនបានទៅខ្ចីសៀវភៅពីសាលា ខ្ញុំស្រាវជ្រាវរឿងតាមទូរស័ព្ទដៃ ឬបើកវីដេអូរឿងនិទានមើលជាមួយគ្នា។ បន្ទាប់ពីអានមួយរយៈ កូនរបស់ខ្ញុំ មានទម្លាប់ទាមទារឱ្យអានសៀវភៅឱ្យស្ដាប់មុនពេលចូលគេង ចាប់ផ្ដើមស្រឡាញ់សៀវភៅរឿង ចេះពាក្យពេចន៍ច្រើន ឆ្ងល់ច្រើន សួរច្រើន ចង់ទៅកន្លែង ផ្សេងៗដែលគាត់បានឮពីក្នុងរឿង ចង់ទិញសៀវភៅរឿង និងរបស់លេងដូចក្នុងរឿងជាដើម។ ខ្ញុំសូមលើកទឹកចិត្តឱ្យមាតាបិតាយកចិត្តទុកដាក់អានសៀវភៅនៅផ្ទះជាមួយកូន ចាត់ទុកថាជាពេលវេលាគ្រួសារកម្សាន្តរីករាយជាមួយគ្នា។»



ឪពុក និងកុមារស្ដាប់ការណែនាំរបៀបខ្ចីសៀវភៅពីសាលារៀន។



ម្ដាយ និងកុមារអានសៀវភៅរួមគ្នានៅផ្ទះ។

Scanned with MOBILE SCANNER

# ជំពូកទី៦
# ការងារបណ្ណាល័យមត្តេយ្យសិក្សា



បណ្ណាល័យសាលារៀនគឺជាឃ្លាំងផ្ទុកនូវចំណេះដឹង ជំនាញ បទពិសោធ រក្សានូវមរតកវប្បធម៌សង្គម សៀវភៅឯកសារ គម្ពីរ ក្បួនច្បាប់ កំណត់ត្រា ព្រឹត្តិការណ៍ផ្សេងៗ ស្នាដៃកេរដំណែល និងសម្ភារឧបទ្ទេស សម្រាប់ធ្វើសកម្មភាពឆ្ពោះទៅរកការអាន។ បណ្ណាល័យផ្សារភ្ជាប់សៀវភៅ និងកុមារ ផ្តល់នូវភាពសប្បាយរីករាយ សេរីភាពក្នុងការប្រាស្រ័យទាក់ទងរវាងកុមារ និងកុមារ កុមារនិងគ្រូ បណ្ណារក្ស សហគមន៍ មានសារៈប្រយោជន៍ធ្វើឱ្យកុមារមានភាពម្ចាស់ការ ក្លាហាន រីកចម្រើនគំនិត ប្រាជ្ញា ការស្រមើស្រមៃ និងមានទំនុកចិត្តខ្ពស់លើខ្លួនឯង។

បណ្ណាល័យបង្កើតបានតាមលទ្ធភាពដូចជា បណ្ណាល័យជ្រុងថ្នាក់(ធ្នើរ ឬកន្លែងដាក់សៀវភៅឯកសារ) បណ្ណាល័យចល័ត(ទូ ឬហិបដាក់សៀវភៅដែលអាចប្តូរទីតាំងបាន)បណ្ណាល័យអេឡិចត្រូនិច បន្ទប់បណ្ណាល័យ និងអគារបណ្ណាល័យ ដែលបម្រើការបង្រៀន និងរៀនរបស់គ្រូ បណ្តុះទម្លាប់កុមារអាន លើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវ ផ្លាស់ប្តូរបរិយាកាស និងលំហែកម្សាន្ត។ កុមាររីករាយជាមួយរឿងនិទាន បត់រូប គូរគំនូរផាត់ពណ៌ សកម្មភាពសិល្បៈងាយៗ ដែលបានជំរុញបន្ថែមដល់កុមារឱ្យកាន់តែចង់អានសៀវភៅ ចង់មករៀន និងចង់ខ្ចីសៀវភៅទៅអាននៅផ្ទះ។

ក្នុងឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡាបានផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ឯកសារស្តង់ដាបណ្ណាល័យបឋមសិក្សា ជាឯកសារគោលជំនួយដល់ការរៀបចំដំណើរការបណ្ណាល័យនៅកម្រិតបឋមសិក្សា។ ដោយឡែក សម្រាប់មត្តេយ្យសិក្សា យើងមិនមានគោលការណ៍ណែនាំណាមួយសម្រាប់ការរៀបចំបណ្ណាល័យមត្តេយ្យសិក្សានោះទេ។ ទោះបីជាយ៉ាងនេះក្តី ក្នុងការរៀបចំថ្នាក់រៀន គ្រូមត្តេយ្យសិក្សាត្រូវរៀបចំជ្រុងសិក្សាដែលយើងចាត់ទុកថាជាបណ្ណាល័យមួយសម្រាប់ថ្នាក់មត្តេយ្យដែរ។ សៀវភៅជាធាតុដ៏សំខាន់ក្នុងជ្រុងនេះ ហើយគួរមានចំនួនយ៉ាងហោចចន្លោះពី២០ ទៅ៥០ក្បាល។

ដូចបានបង្ហាញក្នុងជំពូកទី៥ ការអាននៅសាលា និងនៅផ្ទះសុទ្ធតែមានអត្ថប្រយោជន៍សម្រាប់ការអភិវឌ្ឍរបស់កុមារ។ ការរៀបចំដំណើរការខ្ចី សងសៀវភៅក្នុងថ្នាក់មត្តេយ្យសិក្សាមួយបានរលូន លុះត្រាតែមានប្រព័ន្ធគ្រប់គ្រងសៀវភៅមួយបានល្អ។ ការគ្រប់គ្រងសៀវភៅបានល្អផ្តល់ភាពងាយស្រួលដល់គ្រូខ្លួនឯងផ្ទាល់ កុមារ មាតាបិតា អាណាព្យាបាលជាអ្នកប្រើប្រាស់ ងាយស្រួលរៀបចំផែនការថវិកាទិញសៀវភៅប្រចាំឆ្នាំ សុំការគាំទ្រពីសហគមន៍ និងការបង្ហាញនូវការគ្រប់គ្រងល្អក្នុងសាលារៀន ជាពិសេស កុមារនឹងបន្តអនុវត្តន៍ការប្រើប្រាស់បណ្ណាល័យនៅបឋមសិក្សាព្រោះគេបានបណ្តុះទម្លាប់អានតាំងពីនៅមត្តេយ្យសិក្សារួចជាស្រេច។ ក្នុងជំពូកនេះ យើងនឹងលើកយកពីរបៀបគ្រប់គ្រងសៀវភៅដែលមានលក្ខណៈស្រដៀងគ្នានឹងការគ្រប់គ្រងបណ្ណាល័យបឋមសិក្សា ហើយបានអនុវត្តន៍ក្នុងសាលាមត្តេយ្យសិក្សារង្គជាច្រើន។



## ១. ការគ្រប់គ្រងសៀវភៅ

ការគ្រប់គ្រងសៀវភៅគឺជាការត្រួតពិនិត្យសៀវភៅដែលមាននៅជ្រុងសិក្សា តាមរយៈការចុះបញ្ជីឱ្យមានរបៀបរៀបរយ ក្នុងគោលបំណងបង្កភាពងាយស្រួលដល់គ្រូមត្តេយ្យសិក្សាគ្រប់គ្រងសៀវភៅ និងការប្រើប្រាស់របស់កុមារ។

### ១.១. សារៈសំខាន់នៃការគ្រប់គ្រងសៀវភៅ

ការគ្រប់គ្រងសៀវភៅជួយឱ្យគ្រូមត្តេយ្យសិក្សាបានដឹងអំពី៖

- ចំនួនសៀវភៅដែលថ្នាក់របស់ខ្លួនទទួលបានក្នុងមួយឆ្នាំសិក្សា
- បច្ចុប្បន្នភាពចំនួនសៀវភៅនៅក្នុងថ្នាក់
- ចំនួនសៀវភៅដែលខូច ឬបាត់បង់។

### ១.២. ប្រភេទសៀវភៅ

នៅក្នុងថ្នាក់មត្តេយ្យសិក្សា ឬបណ្ណាល័យ យើងបែងចែកសៀវភៅជា៣ប្រភេទ៖

- សៀវភៅអក្សរសិល្ប៍៖ អ្នកនិពន្ធសរសេររឿងរ៉ាវទៅតាមការយល់ឃើញ ប្រឌិតកថា ឬស្រមើស្រមៃសម្រាប់តែការកម្សាន្តសប្បាយរបស់ខ្លួន ឬអប់រំដោយប្រយោលដល់អ្នកអាន។ បើទោះបីមានផ្នែកខ្លះពិតក៏ដោយ ប៉ុន្តែខ្លឹមសារទាំងមូលមិនពិតឡើយ។



- សៀវភៅព័ត៌មាន៖ អ្នកនិពន្ធសរសេររឿងរ៉ាវពិតទាំងឡាយ ទាក់ទងនឹងទីកន្លែង មនុស្ស ព្រឹត្តិការណ៍ពិតៗ តាមរយៈការស្រាវជ្រាវ ពិសោធន៍ ការជួបប្រទះផ្ទាល់។ល។



Scanned with MOBILE SCANNER

- ទស្សនាវដ្ដី៖ អ្នកនិពន្ធសរសេររឿងរ៉ាវតាមសម័យកាលនីមួយៗ ផ្សាយចេញតាមកាលកំណត់ទៀងទាត់ពី៣ ទៅ៦ខែ ឬ១ឆ្នាំម្ដងជាដើម។ យើងពុំសូវសង្កេតឃើញមានទស្សនាវដ្ដីសមស្រប សម្រាប់ថ្នាក់មត្តេយ្យសិក្សានោះទេ។



## ១.៣. ដំណើរការឯកសារថ្មី

នៅពេលលោកគ្រូ អ្នកគ្រូ ឬបណ្ណារក្សទទួលបានសៀវភៅឯកសារថ្មីៗពីប្រភពផ្សេងៗ ត្រូវបំពេញការងារតាមជំហានដូចខាងក្រោម៖




**ក. ផ្ទៀងផ្ទាត់៖** ដើម្បីឱ្យដឹងចំនួនឯកសារ និងចំនួនចំណងជើងច្បាស់លាស់ ដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សៀវភៅឯកសារនឹងបញ្ជីប្រគល់ ទទួលសៀវភៅឯកសារភ្ជាប់មកជាមួយ និងស្ថានភាពល្អ រហែក ឬសើមជាដើម។ ប្រសិនបើចំនួនសៀវភៅ ឬចំណងជើងមិនដូចក្នុងបញ្ជីប្រគល់ ទទួល យើងត្រូវកត់ចំណាំនៅក្នុងបញ្ជីនោះ ហើយរក្សាទុកបញ្ជីនោះជាឯកសាររដ្ឋបាលថ្នាក់។







**ខ.បោះត្រា៖** ការបោះត្រាលើសៀវភៅឯកសារដើម្បីសម្គាល់ថា សៀវភៅឯកសារនេះជាកម្មសិទ្ធិរបស់សាលារៀន។ ករណីមិនមានត្រាបណ្ណាល័យ យើងអាចបោះត្រាសាលារៀន ព្រោះមានឈ្មោះសាលារៀនសម្គាល់លើសៀវភៅជាស្រេច។ ខាងក្រោមជារបៀបបោះត្រា៖



- បោះនៅទំព័រចំណងជើង គឺទំព័រ១ ឬ២បន្ទាប់ពីក្របមុខនៃសៀវភៅ បោះត្រង់ចំណុចគ្មានអក្សរ ឬរូបភាពប្រសិនបើអាច។ គួរចៀសវាងទីតាំងនៅចុងទំព័រ ព្រោះពេលបើកទំព័រធ្វើឱ្យលុបស្នាមត្រា។
- បោះនៅទំព័រសេសដូចៗគ្នាគ្រប់សៀវភៅ(អាចបោះលើទំព័រគូ ក្នុងករណីទំព័រសេសនៅខាងឆ្វេង)
- បោះនៅទំព័របន្ទាប់ពីក្របក្រោយ។
- សៀវភៅមួយចំនួនបោះត្រាជាប់មិនបានយូរទេ ដូច្នេះយើងអាចបោះនៅលើក្របដែលមានបិទថង់ប្លាស្ទិចការពារ។

**គ.ចុះបញ្ជីរួម៖** បញ្ជីរួម គឺជាបញ្ជីសម្រាប់កត់ត្រាសៀវភៅឯកសារបីប្រភេទរួមមាន សៀវភៅអក្សរសិល្ប៍ ព័ត៌មាន និងទស្សនាវដ្ដី ដែលគ្រូ ឬបណ្ណារក្សបានរៀបចំឡើងដើម្បីងាយស្រួលធ្វើរបាយការណ៍ទាន់ពេលវេលា។ បញ្ជីនេះត្រូវបូកសរុបបិទជារៀងរាល់ឆ្នាំ បង្ហាញពីចំនួនសៀវភៅដែលបានទទួលក្នុងមួយឆ្នាំៗ។ ដើម្បីចុះបញ្ជីរួមបានត្រឹមត្រូវ គ្រូត្រូវប្រមូលព័ត៌មានសំខាន់ដូចខាងក្រោម៖

- កំណត់ត្រាទទួលសៀវភៅ ឬវិក្កយបត្រ៖ លេខវិក្កយបត្រ(បើគ្មានចុះខ្លួនឯង) ថ្ងៃទទួល ចំនួនសរុប ប្រភពផ្ដល់សៀវភៅ(ស្ថាប័ន សប្បុរសជន ថវិកាសាលា...) និងកំណត់ចំណាំផ្សេងៗ(ថ្មី ចាស់ រហែក សើម...)។
- ចំនួន និងចំណាត់ថ្នាក់សៀវភៅ៖ កំណត់ចំនួនចំណងជើង ចំនួនសៀវភៅតាមប្រភេទអក្សរសិល្ប៍ ព័ត៌មាន និងទស្សនាវដ្ដីឱ្យបានច្បាស់ ដែលជាទូទៅគ្រូខ្លួនឯងជាអ្នកកំណត់។

សម្រាប់ទម្រង់បញ្ជីរួម សូមមើលក្នុងឧបសម្ព័ន្ធ។ ខាងក្រោមនេះជាករណីសិក្សា៖

Scanned with Mobile Scanner

**វិភាគវិក្កយបត្រ៖**



ថ្នាក់មត្តេយ្យសិក្សាបានទិញសៀវភៅចំនួន១១ក្បាល ពីទីផ្សារដោយថវិកាសាលារៀនខ្លួនឯងផ្ទាល់។

លេខបញ្ជី ឬវិក្កយបត្រ៖ លើវិក្កយបត្តនេះមិនមានចុះលេខទេ ដូច្នេះ គ្រូចុះលេខខ្លួនឯងលើវិក្កយបត្រ គឺលេខ០០២

គ្រូផ្ទៀងផ្ទាត់ឃើញថាមានសៀវភៅអក្សរសិល្ប៍ ចំនួន៨ចំណងជើង ស្មើនឹង៨ក្បាល

សៀវភៅព័ត៌មានចំនួន៣ចំណងជើង ស្មើនឹង៣ក្បាល

ថ្ងៃ ខែ ឆ្នាំចូល៖ យកថ្ងៃទិញសៀវភៅលើវិក្កយបត្រ។ បើមានកំណត់ត្រាប្រគល់ទទួលសៀវភៅដោយឡែកមួយទៀត យកកាលបរិច្ឆេទប្រគល់ទទួលលើកំណត់ត្រា។

**ចុះបញ្ជីរួម៖**

| ល.រ | ថ្ងៃ ខែ ឆ្នាំចូល | លេខបញ្ជី / វិក្កយបត្រ | សរុបចំនួនចំណងជើង និងចំនួនសៀវភៅ | | | | | | | | ប្រភព | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សៀវភៅ | | | | ទស្សនាវដ្ដី | | សៀវភៅសរុប | | | |
| | | | សៀវភៅអក្សរសិល្ប៍ | | សៀវភៅព័ត៌មាន | | | | | | | |
| | | | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | | |
| ១ | ២២-០៨-២០២១ | ០០២ | ៨ | ៨ | ៣ | ៣ | ០ | ០ | ១១ | ១១ | ថវិកាសាលា | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ៦ | | | | | | | | | | | | |



**ការបិទបញ្ជីរួម៖** ជាទូទៅ ការបិទបញ្ជីរួមធ្វើឡើងតែមួយដងនៅពេលចុងឆ្នាំសារពើពន្ធ(ថ្ងៃទី៣១ ខែធ្នូ)។ ការបិទបញ្ជីរួមអាចឱ្យដឹងពីព័ត៌មានទាក់ទងនឹងចំនួនសៀវភៅចូលក្នុងសាលារៀន ឬថ្នាក់មត្តេយ្យសិក្សាក្នុងមួយឆ្នាំៗ។ នេះជាគំរូនៃការបិទបញ្ជីរួម៖

| ល.រ | ថ្ងៃ ខែ ឆ្នាំចូល | លេខបញ្ជី / វិក្កយបត្រ | សរុបចំនួនចំណងជើង និងចំនួនសៀវភៅ | | | | | | | | ប្រភព | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សៀវភៅ | | | | ទស្សនាវដ្ដី | | សៀវភៅសរុប | | | |
| | | | សៀវភៅអក្សរសិល្ប៍ | | សៀវភៅព័ត៌មាន | | | | | | | |
| | | | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | ចំណងជើង | ចំនួនក្បាល | | |
| ១ | ២២-០៨-២០២១ | ០០២ | ៨ | ៨ | ៣ | ៣ | ០ | ០ | ១១ | ១១ | ថវិកាសាលា | |
| ២ | | | | | | | | | | | | |
| ៣ | បានបញ្ឈប់បញ្ជីត្រឹមលេខរៀងទី១ មានចំនួន១វិក្កយបត្រ ស្មើនឹង១១ចំណងជើង សរុបសៀវភៅ១១ក្បាល។ | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |

ថ្ងៃ..........ខែ.......... ឆ្នាំ.........ស័ក ព.ស.២៥៦....

ធ្វើនៅ........... ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២..

គ្រូបន្ទុកថ្នាក់

បានឃើញ និងឯកភាព

នាយកសាលា

**ឃ.ដាក់លេខកូដឌីវេ៖** ដើម្បីសម្គាល់ប្រភេទសៀវភៅ(ភាសា អក្សរសាស្ត្រ អក្សរសិល្ប៍...) គេបានប្រើប្រាស់នូវប្រព័ន្ធសម្គាល់ផ្សេងៗ ដូចជាប្រើពណ៌ ប្រើរូបភាពតំណាង ឬលេខកូដ។ ក្នុងឯកសារនេះ យើងសូមណែនាំពីវិធីសាស្ត្រសម្គាល់ប្រភេទសៀវភៅដោយប្រើប្រាស់លេខកូដឌីវេ។ ប្រព័ន្ធកូដឌីវេត្រូវបានដាក់ឱ្យប្រើប្រាស់ជាលើកដំបូងនៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ១៨៧៦ ដែលបានបង្កើតឡើងដោយលោក Melvil Dewey ជាជនជាតិអាមេរិក និងជាអតីតបណ្ណារក្ស។ ប្រព័ន្ធកូដនេះមានភាពពេញនិយម ហើយត្រូវបានយកទៅប្រើប្រាស់ដោយស្ថាប័នជាច្រើនជុំវិញពិភពលោក។ នៅក្នុងស្តង់ដារបណ្ណាល័យបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ប្រើប្រាស់ប្រព័ន្ធលេខកូដនេះដែរ។ ខាងក្រោមនេះជាចំណាត់ថ្នាក់លេខកូដឌីវេសង្ខេប៖

| **លេខកូដ** | **ចំណាត់ថ្នាក់** | **ប្រភេទសៀវភៅ** |
|---|---|---|
| ០០០ | ស្នាដៃទូទៅ | កុំព្យូទ័រ វចនានុក្រម សព្វវចនាធិប្បាយ សាមាយិកបត្រ ទស្សនាវដ្តី កាសែត និងប្រព័ន្ធផ្សព្វផ្សាយ |
| ១០០ | ទស្សនវិជ្ជានិង ចិត្តវិទ្យា | ទស្សនវិជ្ជា ចិត្តវិទ្យា និងក្រមសីលធម៌ |
| ២០០ | សាសនា | សាសនា ពុទ្ធសាសនា គ្រីស្តសាសនា សាសនាផ្សេងៗ និងវប្បធម៌ |

Scanned with MOBILE SCANNER

| លេខកូដ | ចំណាត់ថ្នាក់ | ប្រភេទសៀវភៅ |
|---|---|---|
| ៣០០ | វិទ្យាសាស្ត្រសង្គម | ការរស់នៅរបស់ប្រជាជន ការងារក្នុងសង្គម ច្បាប់ រដ្ឋាភិបាល សេដ្ឋកិច្ច ការអប់រំ ពាណិជ្ជកម្ម ការទំនាក់ទំនង មធ្យោបាយធ្វើដំណើរ ពន្ធគយ និងអតិថិនីយ |
| ៤០០ | ភាសា | រៀនភាសាខ្មែរ រៀនអង់គ្លេស វេយ្យាករណ៍ ភាសាផ្សេងៗ ភាសា និងសញ្ញាភាសា |
| ៥០០ | វិទ្យាសាស្ត្រពិត | គណិតវិទ្យា តារាវិទ្យា រូបវិទ្យា គីមី ជីវវិទ្យា បរិស្ថានវិទ្យា ការសិក្សាអំពីសត្វ រុក្ខវិទ្យា |
| ៦០០ | បច្ចេកវិទ្យា (វិទ្យាសាស្ត្រអនុវត្ត) | កសិកម្ម សុខភាព អនាម័យ ជម្ងឺ ថ្នាំពេទ្យ ការរៀបចំផ្ទះ សេដ្ឋកិច្ច ធ្វើម្ហូប ការចិញ្ចឹមអប់រំកូន កាត់ដេរ វិស្វករ ផលិតកម្ម សំណង់អាគារ |
| ៧០០ | សិល្បៈ និងការកំសាន្ត | សិល្បៈ សូន្យរូប ស្ថាបត្យកម្ម ចម្លាក់ គំនូរ ផាត់ពណ៌ គ្រឿងសង្ហារិម តន្ត្រី រូបថត ខ្សែភាពយន្ត កីឡា |
| ៨០០ | អក្សរសិល្ប៍ | សៀវភៅរឿង អក្សរសិល្ប៍ កំណាព្យ សរសេរ អក្សរសិល្ប៍បរទេស |
| ៩០០ | ប្រវត្តិវិទ្យា និងភូមិវិទ្យា | ប្រវត្តិវិទ្យា ជីវប្រវត្តិ និងភូមិវិទ្យា |

**បញ្ជាក់៖** ក្នុងបរិបទមត្តេយ្យសិក្សា ភាគច្រើនយើងប្រើតែលេខកូដ ៨០០ ៥០០ និង៤០០ប៉ុណ្ណោះ។

**របៀបបិទលេខកូដ៖**




- ចងចាំលេខកូដធំទាំង១០របស់ជីវ
- សរសេរលើស្លាកកូដ(បកបិទ)នូវលេខកូដ និងត្រកូលអ្នកនិពន្ធ ឬអ្នករៀបរៀងយ៉ាងច្រើនបីព្យាង្គនៅពីក្រោមលេខកូដ (បីតួអក្សរសម្រាប់ភាសាបរទេស)។ បើរកអ្នកនិពន្ធមិនឃើញ យកចំណងជើងបីព្យាង្គដូចគ្នា
- បិទស្លាកកូដលើក្របមុខ កម្ពស់២ស.មពីបាត បិទស្កុតបន្ថែមពីលើស្លាកកូដ។

**៨០០៖** លេខកូដប្រភេទអក្សរសិល្ប៍

**ជិន៖** អ្នកនិពន្ធឈ្មោះ ជិន យ៉ាហន

**ង.ចុះបញ្ជីសារពើភ័ណ្ឌសៀវភៅ៖** បញ្ជីសារពើភ័ណ្ឌប្រើប្រាស់សម្រាប់ចុះកំណត់ត្រាគ្រប់សៀវភៅទាំងអស់នៅបណ្ណាល័យ ឬថ្នាក់មត្តេយ្យសិក្សា។ នៅក្នុងបញ្ជីមានចុះចំណងជើងសៀវភៅ ឈ្មោះអ្នកនិពន្ធ រោងពុម្ព ឆ្នាំបោះពុម្ព លេខកូដជីវ ប្រភពផ្តល់ និងផ្សេងៗជាដើម។

ដើម្បីចុះបញ្ជីសារពើភ័ណ្ឌបានរហូន យើងត្រូវចុះលេខសារពើភ័ណ្ឌជាមុន។ លេខកូដសារពើភ័ណ្ឌជាលេខរៀងសម្រាប់សម្គាល់សៀវភៅដែលចុះតាមលំដាប់លំដោយមានតែមួយគត់សម្រាប់សៀវភៅមួយក្បាល បើទោះបីជាសៀវភៅមានចំណងជើងដូចគ្នាក៏ដោយ ហើយលេខសារពើភ័ណ្ឌត្រូវផ្តើមចេញពី០០០១។ លេខសារពើភ័ណ្ឌចុងក្រោយគេបង្ហស់គឺជាចំនួនសៀវភៅដែលធ្លាប់មាននៅក្នុងបណ្ណាល័យ រីឯចំនួនសៀវភៅ ជាក់ស្តែងគឺសល់ពីសៀវភៅបាត់ និងខូច។

**លេខកូដជីវេ**សម្រាប់សម្គាល់ប្រភេទសៀវភៅ។ សៀវភៅជាច្រើនមានលេខកូដជីវដូចគ្នា។
**លេខសារពើភ័ណ្ឌ**សម្រាប់សម្គាល់លេខរៀងសៀវភៅ។ សៀវភៅមួយក្បាលមានលេខសារពើភ័ណ្ឌតែមួយគត់។

**របៀបចុះលេខសារពើភ័ណ្ឌលើសៀវភៅ៖**




Scanned with MOBILE SCANNER

## របៀបចុះបញ្ជីសារពើភ័ណ្ឌ៖




ព័ត៌មានសំខាន់ៗ៖

- រឿង ដំរីចិត្តបុណ្យ
- ចូលនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១
- អ្នកនិពន្ធឈ្មោះ ជិន យ៉ាហន
- បោះពុម្ពដោយ អង្គការសន្តិស័គ្រចិត្ត(SVA)
- បោះពុម្ពនៅឆ្នាំ២០០៩
- លេខកូដសៀវភៅ ៨០០
- លេខសារពើភ័ណ្ឌ ០០១៦
- ប្រភព៖ ថវិកាសាលារៀន

*បញ្ជាក់៖ សម្រាប់ព័ត៌មានទូទៅអំពីសៀវភៅ សូមស្វែងរកនៅក្របខាងមុខ ក្របខាងក្រោយ ទំព័រទី១ ឬទី២រាប់បន្ទាប់ពីក្របមុខ ឬទំព័រទី១ ឬទី២រាប់ពីក្របក្រោយនៃសៀវភៅ។*




តាមរយៈព័ត៌មានខាងលើ យើងអាចចុះបញ្ជីសៀវភៅរឿង ដំរីចិត្តបុណ្យដូចខាងក្រោម។ សម្រាប់គំរូទម្រង់បញ្ជីសារពើភ័ណ្ឌ សូមយកស្វែងរកក្នុងឧបសម្ព័ន្ធ។

| លេខសារពើភ័ណ្ឌ | ថ្ងៃ ខែ ឆ្នាំចូល | ឈ្មោះអ្នកនិពន្ធ | ចំណងជើងសៀវភៅ | គ្រឹះស្ថានបោះពុម្ពផ្សាយ | ឆ្នាំបោះពុម្ព | លេខកូដសៀវភៅ | ប្រភពផ្តល់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ០០០១ | ១២-០៧-២០២១ | ហួត វិច្ឆកា | សៀវភៅរូបភាពយានជំនិះ | ស៊ីប៉ា | ២០១៤ | ៤០០ | ថវិកាសាលា | |
| ០០០២ | ១២-០៧-២០២១ | ហួត វិច្ឆកា | សៀវភៅរូបភាពយានជំនិះ | ស៊ីប៉ា | ២០១៤ | ៤០០ | ថវិកាសាលា | |
| ០០០៣ | ១២-០៧-២០២១ | ម៉ឹង រដ្ឋា | សៀវភៅរូបភាពអាហារ | ស៊ីប៉ា | ២០១៥ | ៤០០ | ថវិកាសាលា | |
| ០០០៤ | ១២-០៧-២០២១ | ម៉ឹង រដ្ឋា | សៀវភៅរូបភាពអាហារ | ស៊ីប៉ា | ២០១៥ | ៤០០ | ថវិកាសាលា | |
| ០០០៥ | ១២-០៧-២០២១ | ម៉ឹង រដ្ឋា | សៀវភៅរូបភាពអាហារ | ស៊ីប៉ា | ២០១៥ | ៤០០ | ថវិកាសាលា | |
| ០០០៦ | ១២-០៧-២០២១ | ផ្លូវណេ | សៀវភៅរូបភាពកម្សាន្ត | ស៊ីប៉ា | ២០១៥ | ៤០០ | ថវិកាសាលា | |
| ០០០៧ | - | - | - | - | - | - | - | |
| ០០០៨ | - | ប្រើសញ្ញាគ្រេសម្រាប់ព័ត៌មានដូចគ្នា | | | - | - | - | |
| ០០០៩ | - | - | - | - | - | - | - | |
| ០០១០ | ២២-០៨-២០២១ | តាជីម៉ា ស៊ីនជី | កុលាបពីរទង | SVA | ២០១៤ | ៨០០ | អង្គការ SVA | |
| ↓ | | ប្រើសញ្ញាបំព្រួញជំនួសឱ្យការសរសេរលេខរៀង | | | | | | |
| ០០១៥ | | | | | | | | |
| ០០១៦ | ២២-០៨-២០២១ | ជិន យ៉ាហន | ដំរីចិត្តបុណ្យ | SVA | ២០០៩ | ៨០០ | ថវិកាសាលា | |
| ០០១៧ | | | | | | | | |
| ០០១៨ | | | | | | | | |

សម្គាល់៖

- ឈ្មោះអ្នកនិពន្ធ៖ សរសេរឈ្មោះពេញរបស់អ្នកនិពន្ធ តែមិនសរសេរគោរមងារ
- ទស្សនាវដ្តីមិនចុះក្នុងបញ្ជីសារពើភ័ណ្ឌ
- ចំណុចផ្សេងៗនៃបញ្ជីសារពើភ័ណ្ឌសៀវភៅ ត្រូវសរសេរក្នុងករណីមានអ្វីបន្ថែម(សៀវភៅបាត់ ឬខូច)
- ការចុះបញ្ជីសារពើភ័ណ្ឌសៀវភៅត្រូវធ្វើក្នុងរយៈពេល១ខែយ៉ាងយូរ បន្ទាប់ពីចុះបញ្ជីរួចរាល់។
- ចំពោះសៀវភៅភាសាបរទេស សូមប្រឹក្សាយោបល់ជាមួយអ្នកជំនាញដើម្បីស្វែងរកព័ត៌មានក្នុងតារាងខាងលើ។

Scanned with MOBILE SCANNER

**៦. ដាក់ក្របសៀវភៅ៖** ដើម្បីឱ្យសៀវភៅអាចប្រើបានយូរ យើងត្រូវដាក់ក្របប្លាស្ទិច។ សូមមើលលម្អិតនៅផ្នែកបន្ទាប់។

**៨. រៀបចំសៀវភៅដាក់ធ្នើរ៖** បន្ទាប់ពីចុះបញ្ជីសារពើភ័ណ្ឌរួចហើយ ត្រូវរៀបចំសៀវភៅដាក់លើធ្នើរ បើសល់មួយចំនួនត្រូវរក្សាទុកឱ្យមានរបៀប។ ការរៀបចំអាចបត់បែនតាមស្ថានភាពធ្នើរ ស្ថានភាពសៀវភៅ និងបរិមាណសៀវភៅ។ ខាងក្រោមនេះជាគន្លឹះខ្លះៗ៖

- តាំងបង្ហាញរូបភាពចំណងជើងសៀវភៅតាមលទ្ធភាពដែលអាចធ្វើបាន
- រៀបដាក់សៀវភៅតាំងពីឆ្វេងទៅស្តាំ បើសៀវភៅស្តើងត្រូវដាក់សង្កត់បន្តគ្នា ធ្វើបែបនេះជួយរក្សាលំនឹងសៀវភៅ ហើយនៅតែអាចមើលឃើញក្របមុខបានមួយភាគធំ
- រៀបសៀវភៅដែលប្រភេទ ឬទំហំស្រដៀងគ្នាបង្កើនសោភណភាពធ្នើរ
- បើមានសៀវភៅច្រើន ប្តូរចំណងជើងរឿងជាប្រចាំ ដូចជា១សប្តាហ៍ម្តង
- បើមានលទ្ធភាព រៀបចំកន្លែងសម្រាប់ដាក់តាំងសៀវភៅមកដល់ថ្មី ឬសៀវភៅណាដែលចង់ឱ្យកុមារចាប់អារម្មណ៍អាន។







## ២. ការខ្ចី សងសៀវភៅ

### ២.១. ដំណើរការខ្ចី សងសៀវភៅ




Scanned with MOBILE SCANNER

**បញ្ជីខ្ចី សងសៀវភៅ៖** ក្រៅពីបញ្ជីរួម និងបញ្ជីសារពើភ័ណ្ឌ គ្រូត្រូវមានបញ្ជីខ្ចី សងមួយទៀតសម្រាប់គ្រប់គ្រងការខ្ចី សងសៀវភៅក្នុងថ្នាក់មត្តេយ្យសិក្សា។ ព័ត៌មានទាក់ទងនឹងសៀវភៅមានគ្រប់គ្រាន់ ប្រសិនបើសៀវភៅនោះបានចុះក្នុងបញ្ជីសារពើភ័ណ្ឌរួចរាល់។ ខាងក្រោមជាឧទាហរណ៍ការចុះបញ្ជីខ្ចី សង៖

| ល.រ | ឈ្មោះអ្នកខ្ចី | ភេទ | តួនាទី | ចំណងជើងសៀវភៅ | លេខសារពើភ័ណ្ឌសៀវភៅ | កាលបរិច្ឆេទខ្ចី | | កាលបរិច្ឆេទសង | | ហត្ថលេខាគ្រូបណ្ណារក្ស ឬ បណ្ណារក្ស | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ថ្ងៃខ្ចី | ហត្ថលេខា | ថ្ងៃសង | ហត្ថលេខា | | |
| ១ | សុខ រី | ស | កុមារកម្រិតខ្ពស់ | សៀវភៅរូបភាពជុំវិញខ្លួន | ០០២០ | ១៤-០៣-២០២១ | ✓ | ១៥-០៣-២០២១ | ✓ | [signature] | |
| ២ | ឃុន សារិន | ប | អាណាព្យាបាល | សៀវភៅរូបភាពកម្ពុជា | ០០១០ | ១៤-០៣-២០២១ | [signature] | ១៥-០៣-២០២១ | [signature] | [signature] | រើបាកក្របពេលសងត្រឡប់ |
| ៣ | ប៊ុត ណាត | ស | កុមារកម្រិតខ្ពស់ | រឿង ជីវិតខ្ញុំបុណ្យ | ០០១៦ | ១៤-០៣-២០២១ | ណាត | ១៦-០៣-២០២១ | ណាត | [signature] | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**សម្គាល់៖** កុមារតូចភាគច្រើនមិនទាន់ចេះចុះហត្ថលេខាទេ ដូច្នេះ ប្រើសញ្ញាសម្គាល់ងាយៗបាន។

## ២.២. ការបង្កើតគោលការណ៍ខ្ចី សងសៀវភៅ

មុនពេលបើកឱ្យមានការខ្ចីសៀវភៅ គ្រូត្រូវរៀបចំបង្កើតគោលការណ៍ខ្ចី សងសៀវភៅ និងពន្យល់កុមារ មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ ។ នេះជាគំរូគោលការណ៍ខ្ចី សង៖

### គោលការណ៍ខ្ចី សងសៀវភៅ

- មាតាបិតា ឬអ្នកអាណាព្យាបាលកុមារអាចខ្ចីសៀវភៅបានម្នាក់ត្រឹមតែ...............ក្បាល
- មាតាបិតា ឬអ្នកអាណាព្យាបាលកុមារអាចខ្ចីសៀវភៅរយៈពេលយ៉ាងយូរ............ថ្ងៃ
- មាតាបិតា ឬអ្នកអាណាព្យាបាលកុមារមិនទាន់សងសៀវភៅចាស់មិនអនុញ្ញាតឱ្យខ្ចីសៀវភៅថ្មីទេ
- សូមថែរក្សាសៀវភៅឱ្យបានល្អ និងបង្ការការខូចខាតផ្សេងៗ។

សូមអរគុណ!!



## ៣. ការការពារ និងថែរក្សាសៀវភៅ

មានកត្តាមួយចំនួនដែលអាចបង្កឱ្យសៀវភៅបាត់បង់ និងខូចគុណភាពដូចជា កត្តាមនុស្ស សត្វចង្រៃ និងកត្តាធម្មជាតិ។ មានកត្តា២យ៉ាងដែលធ្វើឱ្យសៀវភៅខូចខាត៖

| កត្តាធម្មជាតិ | កត្តាមនុស្ស |
|---|---|
| <br>- សំណើម ឬកំដៅ<br>- ធូលី<br>- សត្វ(សត្វល្អិត កណ្តៀរ កណ្តុរ កន្លាត តុកកែ ប្រចៀវ) | <br>- ការប្រើប្រាស់សៀវភៅមិនប្រុងប្រយ័ត្ន ខ្ជីខ្ជា<br>- បំផ្លាញដោយចេតនា<br>- ខ្វះអនាម័យ(ប៉ះសៀវភៅពេលដៃកខ្វក់) |

**ដំបូន្មានចំពោះអ្នកខ្ចីសៀវភៅ**

**របៀបថែទាំសៀវភៅ ដើម្បីប្រើប្រាស់ឱ្យបានយូរអង្វែង**

ដើម្បីចៀសវាងនូវការបំផ្លាញដូចខាងលើនេះ ជាគន្លឹះមួយចំនួន៖

**ក. រក្សាសៀវភៅនៅកន្លែងសមស្រប**



- ចៀសវាងកំដៅ និងសំណើម
- អនាម័យនៅកន្លែងទុកដាក់សៀវភៅជាប្រចាំ
  - ឧស្សាហ៍បោស ជូតសម្អាត
  - បង្ការសត្វបំផ្លាញ(បិទទ្វារ បង្អួច)។

**ខ. ពន្យល់ដល់មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ**

- ណែនាំសិស្សពីរបៀបប្រើប្រាស់សៀវភៅ
- យក ឬដាក់សៀវភៅលើធ្នើរ ឬទូដោយប្រុងប្រយ័ត្ន។

Scanned with MOBILE SCANNER



- ណែនាំអ្នកប្រើប្រាស់ពីរបៀបប្រើប្រាស់សៀវភៅឱ្យបានត្រឹមត្រូវ ដូចជា៖
  - បើកសៀវភៅអានដោយដាក់លើផ្ទៃរាបស្មើ
  - ត្រូវបើកទំព័រតាមទិសសៀវភៅដោយប្រុងប្រយ័ត្ន ដោយចាប់បើកពីជ្រុងខាងលើ ឬខាងក្រោមប៉ែកខាងស្តាំដៃ
  - បើកសៀវភៅថ្មីៗ ដាក់អានលើភ្លៅ ឬលើតុ
  - ប្រើវត្ថុស្តើងសម្រាប់កំណត់ចំណាំទំព័របើចាំបាច់
  - សម្អាតដៃមុនពេលកាន់សៀវភៅ
  - ជូសជុលសៀវភៅជាប្រចាំ
  - ណែនាំកុមារឱ្យរាយការណ៍ជម្រាបគ្រូនៅពេលឃើញមានសៀវភៅរហែក
- ពេលវិស្សមកាល ត្រូវរៀបចំទុកដាក់សៀវភៅ នៅកន្លែងមានសុវត្ថិភាពនៅទីតាំងខ្ពស់ ដើម្បីបង្ការករណីទឹកលិច។

**គ. ការការពារ និងថែរក្សា**

- ដាក់ក្របប្លាស្ទិច បិទស្កុតគែមទំព័រក្រប ជួសជុលសៀវភៅដោយបិទស្កុត ឬដេរ។




**ឃ. ពន្យល់ពីសារៈសំខាន់នៃសៀវភៅ៖**

ជាការពិតណាស់ កុមារតូចៗមិនបានយល់ពីរបៀបប្រើប្រាស់សៀវភៅឱ្យបានត្រឹមត្រូវនោះទេ ហើយពេលខ្លះធ្វើឱ្យខូចសៀវភៅថែមទៀតផង។ យើងចាំបាច់ត្រូវពន្យល់ពីសារៈសំខាន់ និងតម្លៃរបស់សៀវភៅឱ្យកុមារបានដឹង។ សៀវភៅសម្រាប់មត្តេយ្យសិក្សាជាទ្រព្យសម្បត្តិរបស់អ្នកគ្រប់គ្នា មិនមែនសម្រាប់តែអ្នកណាម្នាក់នោះទេ។ សៀវភៅទាំងនេះឧបត្ថម្ភដោយសហគមន៍ សាលារៀនផ្ទាល់ខ្លួនឯង និងសប្បុរសជននានា។ សៀវភៅសម្រាប់អ្នកទាំងអស់គ្នា ដូច្នេះ អ្នកទាំងអស់គ្នាត្រូវជួយថែទាំសៀវភៅ។ ការថែទាំងសៀវភៅមិនឱ្យដាច់ ឬរហែក ធ្វើឱ្យយើងទាំងអស់គ្នាប្រើប្រាស់បានស្ថិតស្ថេរយូរអង្វែង។ ការណែនាំកុមារឱ្យប្រើប្រាស់សៀវភៅដោយប្រុងប្រយ័ត្នជួយឱ្យកុមារចេះថែរក្សាទ្រព្យសម្បត្តិសាធារណៈ។



Scanned with
MOBILE SCANNER